**BMI0196**

# សម្ភាសន៍ជាមួយឈ្មោះ កៅ ផាន ភេទប្រុស អាយុ៥៨ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ «កងដឹកជញ្ជូនថ្មនិងខ្សាច់ទៅអាងត្រពាំងថ្ម»
# សព្វថ្ងៃរស់នៅភូមិតាវ៉ង ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ សោម ប៊ុនថន
# ០០:៥០:០២ និង ០០:៥៤:២១
# ៦១ទំព័រ

ប៊ុនថន ៖ អញ្ជើញខ្ញុំសុំសួរឈ្មោះពូ?

ផាន ៖ ខ្ញុំឈ្មោះ កៅ ផាន ។

ប៊ុនថន ៖ ឈ្មោះអីវិញពូ?

ផាន ៖ ឈ្មោះ កៅ ផាន ។

ប៊ុនថន ៖ ឈ្មោះ កៅ ផា ។ លោកពូអាយុប៉ុន្មានហើយ?

ផាន ៖ អាយុ៥៨ឆ្នាំ ។

ប៊ុនថន ៖ អ្ហ៎! ៥៨ឆ្នាំប៉ុនពូ មាំណាស់ ។ (សើច)

ផាន ៖ (សើច)

ប៊ុនថន ៖ ដូចនៅក្មេង ។

ផាន ៖ ស៊ីតែប្រហុក ។

ប៊ុនថន ៖ បាទ! លោកពូកើតនៅភូមិ ឃុំ ណាដែរពូ? ភូមិឃុំស្រុកកំណើតណាពូ?

ផាន ៖ នៅទីនេះឯង ។

ប៊ុនថន ៖ ភូមិអីវិញពូ?

ផាន ៖ ភូមិតាវ៉ង ឃុំទន្លេ ស្រុក ភ្នំស្រុក ។

ប៊ុនថន ៖ ស្រុកភ្នំស្រុក ។ នៅទីនេះមិនមែនស្រុក ព្រះនេត្រព្រះទេ?

ផាន ៖ ទេ ស្រុកភ្នំស្រុក ។ ពីដើមមិញ គេហៅខេត្តបាត់ដំបង តែឥឡូវគេហៅខេត្តបន្ទាយមានជ័យ ។

ប៊ុនថន ៖ គេបំបែកខេត្ត ។ នៅឆ្នាំណាមកខេត្តបន្ទាយមានជ័យ?

ផាន ៖ ទេ ដូចមិនដឹងថាគេបំបែកឆ្នាំប៉ុន្មានទេ គ្រាន់តែដឹងថាសព្វថ្ងៃ គេហៅ បន្ទាយមានជ័យ ។

ប៊ុនថន ៖ ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ផាន ៖ ខ្ញុំមានបងប្អូនបួននាក់ ប្រាំនាក់ទាំងអាចញ្ចឹងមួយ ។

ប៊ុនថន ៖ ប្រាំនាក់ ។ ប្រុសប៉ុន្មាន ស្រីប៉ុន្មានពូ?

ផាន ៖ ប្រុសពីរស្រីបី ។

ប៊ុនថន ៖ ប្រុសពីរស្រីបី ។ ពូកូនទីប៉ុន្មានពូ?

ផាន ៖ ខ្ញុំកូនទីបួន ។

ប៊ុនថន ៖ កូនទីបួន ។

ផាន ៖ បងស្រីបី ហើយប្រុសពីក្រោយ គឺខ្ញុំ ហើយនឹងអាប្អូនខ្ញុំមួយទៀត ។

ប៊ុនថន ៖ ចុះពូមានបានរៀនសូត្រដល់ណាដែរលោកពូ?

ផាន ៖ ខ្ញុំរៀនបានចប់ថ្នាក់ទីប្រាំបី ។

ប៊ុនថន ៖ ថ្នាក់ទីប្រាំបី ។

ផាន ៖ ទីប្រាំបីចាស់ ។

ប៊ុនថន ៖ ថ្នាក់ទីប្រាំបី ។ ដប់ពីរ ដប់មួយ ដប់ ប្រាំបួន ប្រាំបី!

ផាន ៖ រៀនបានប្រាំឆ្នាំ ។

ប៊ុនថន ៖ បាទអញ្ចឹងវាស្មើនឹងថ្នាក់ទីប្រាំយើងឥឡូវ ។ (សើច)

ផាន ៖ (សើច)

ប៊ុនថន ៖ ពូ កាលនោះរៀននៅសាលាណាពូ?

ផាន ៖ ខ្ញុំរៀននៅឯនេះឯង ។

ប៊ុនថន ៖ គេហៅថាសាលាអីវិញពូ?

ផាន ៖ សាលាបឋម តាវង ។

ប៊ុនថន ៖ សាលាបឋមសិក្សា តាវង ។

ផាន ៖ គេហៅពីសង្គម ។ ពីដើមមិញ មានត្រឹមតែថ្នាក់ទីប្រាំបួនទេ ។ ប៉ុន្តែខ្ញុំទៅរៀននៅស្រុកស្វាយចេក មួយឆ្នាំនៅថ្នាក់ទីប្រាំបី ។

ប៊ុនថន ៖ ស្រុកស្វាយចេកអីពូ?

ផាន ៖ បាទ ។

ប៊ុនថន ៖ រៀននៅនេះចប់មួយឆ្នាំ ហើយបានទៅរៀននៅនោះពូ?

ផាន ៖ បាទ ។

ប៊ុនថន ៖ ទៅរៀននៅនោះ ពូនៅជាមួយពីណាគេវិញ?

ផាន ៖ ទៅនៅជាមួយអ៊ំ ។

ប៊ុនថន ៖ អ៊ូ! មានអ៊ំម្នាក់ដែរ?

ផាន ៖ បាទ ។

ប៊ុនថន ៖ អ៊ំខាងម្តាយ ឬខាងឪពុក?

ផាន ៖ អ៊ំខាងឪពុក ។ ប៉ុន្តែសព្វថ្ងៃគាត់ស្លាប់អស់ហើយ ។ គាត់ទៅស្រុកបារាំងទៅ ក៏ចាស់ទៅ...

ប៊ុនថន ៖ អ៊ូ! គាត់បានទៅដល់ស្រុកបារាំងទៀត ។ គាត់ទៅកាលពីជំនាន់ណាពូ?

ផាន ៖ គាត់ទៅសម័យជំរុំនេះណា៎ ។

ប៊ុនថន ៖ ក្រោយ៧៩ ទេអីពូ?

ផាន ៖ ក្រោយ ។

ប៊ុនថន ៖ ចុះពូទៅណោះបានមួយឆ្នាំ ចេញពីនោះពូទៅណាទៀតពូ?

ផាន ៖ ដល់ពេលស្រុកមានសង្គ្រាមពេកទៅ ក៏ឈប់រៀនទៅ ។ ឈប់ហើយក៏មកផ្ទះវិញ ។

ប៊ុនថន ៖ សង្គ្រាមឆ្នាំណាទៅពូ? សង្គ្រាមក្រោយរដ្ឋប្រហារឆ្នាំ១៩៧០យ៉ាងម៉េចពូ?

ផាន ៖ ឆ្នាំ៧០នោះឯង ។ ដល់តែយូរពេកទៅ ចំណាំវាមិនបាន ក៏ភ្លេចទៅ ។

ប៊ុនថន ៖ ចុះឪពុកម្តាយពូគាត់នៅរស់ដែរសព្វថ្ងៃនេះ?

ផាន ៖ ទេ ស្លាប់អស់ហើយសព្វថ្ងៃនេះនោះ ។

ប៊ុនថន ៖ ស្លាប់ជំនាន់ណាដែរពូ?

ផាន ៖ ឪពុកខ្ញុំស្លាប់តាំងពីខ្ញុំនៅកូនង៉ា មិនបានឃើញមុខគាត់ផង ។ បើម្តាយគាត់ស្លាប់ឆ្នាំទៅមិញ ។

ប៊ុនថន ៖ បាទ តាំងពីពូនៅក្មេងៗ ឪពុកអី ។

ផាន ៖ គាត់ស្លាប់តាំងពីកូនង៉ាម៉្លេះ ។

ប៊ុនថន ៖ គាត់ស្លាប់ដោយសារអីពូ?

ផាន ៖ ដោយសារកើតជំងឺធ្លាក់ឈាម ។

ប៊ុនថន ៖ គាត់ជាអ្នកធ្វើការ ឬក៏...

ផាន ៖ គាត់ធ្វើស្រែ ។

ប៊ុនថន ៖ គាត់ជាអ្នកស្រែ ។ ចុះម្តាយលោកពូ?

ផាន ៖ គាត់អ្នកស្រែដូចគ្នា ។

ប៊ុនថន ៖ គាត់ស្លាប់ដែរអីពូ?

ផាន ៖ គាត់ស្លាប់កាលពីឆ្នាំទៅមិញ ។

ប៊ុនថន ៖ លោកពូ កាលពេលត្រឡប់មកផ្ទះ ពូធ្វើអីវិញ? ពេលរៀនត្រឡប់ពីស្វាយចេក?

ផាន ៖ ទេ មានអី មានតែធ្វើស្រែ ។

ប៊ុនថន ៖ ជួយធ្វើស្រែឪពុកម្តាយ ។

ផាន ៖ បាទ ។

ប៊ុនថន ៖ ចុះកាលនោះ ពូមានចូលកង ចូលអីដែរទេ?

ផាន ៖ ចូលកងសម័យ?

ប៊ុនថន ៖ ចូលកងសម័យប៉ីឆ្នាំណា?

ផាន ៖ សម័យឆ្នាំនោះ ខ្ញុំចូលកងដែរតើ ។

ប៊ុនថន ៖ អ្ហ៎! ដូចថាមានគេរើសចូលកងដែរ? ណ៎ាពូ!

ផាន ៖ ដល់ពេលខ្ញុំមកដល់ផ្ទះទៅគឺដល់ពេលគេរើសទាហានខ្លាំង ។ អានោះសម័យ លន់ ណល់ នោះណ៎ា ។ ដល់គេរើសទាហានខ្លាំងទៅ ខ្ញុំចាប់ស្លាកទាហានពីរដង ។ ចាប់ខុសទាំងពីរដង ។

ប៊ុនថន ៖ ចាប់អីគេវិញពូ?

ផាន ៖ ចាប់ស្លាកទាហានដូចថាមួយក្រុមហ្នឹងណា ។ ឧទាហរណ៍ថាចាប់ដាក់មួយក្រុមដប់នាក់ អីហ្នឹង សម័យ លន់ នល់ អីណា ។ គេដាក់តាមភូមិទៅណាមួយក្រុមដប់នាក់ៗ ។ គេចាប់ដាក់មួយក្រុមដប់នាក់ ហើយធ្វើស្លាកមួយទៅណា ។ ចាប់ទាហានណា ឧបមាថាមួយក្រុមគេយកពីរនាក់សម័យ លន់ ណន់ អញ្ចឹងទៅណ៎ា! អាស្លាកក្រោម គេយកតែពីរទេ ក្នុងដប់នាក់នោះណា ។

ប៊ុនថន ៖ មានតែពីរទេ?

ផាន ៖ នោះហើយ ។ ហើយដល់ពេលចាប់ទៅ ខ្ញុំចាប់ពីរដង ខុសទាំងពីរដង ។ ដល់ពេលក្រោយមកគេឲ្យយាមដង ។ អាយាមក៏យាម អាចាប់ក៏ចាប់ ។ ដូចថាយាមគេហៅស្ម័យត្រាណ ។

ប៊ុនថន ៖ ក្នុងភូមិអីពូ?

ផាន ៖ បាទ!

ប៊ុនថន ៖ យាមនៅក្នុងភូមិហ្នឹងអីពូ?

ផាន ៖ បាទ យាមនៅក្នុងភូមិ ។ កាលនោះ ទាហាន លន់ ណល់ មិនទាន់ចូលមកដល់ទេ ។ ដល់ពេលគេឲ្យចូលយាមទាហានផង គេឲ្យចាប់ស្លាកទាហាន ។ ដល់ពេលដែលខ្ញុំចាប់ខុសទៅវាចេះតែរើស ហើយចេះតែញីងណា ហើយក៏ដេញខ្ញុំឲ្យទៅនៅវត្ត ។

ប៊ុនថន ៖ ទៅវត្តណាវិញ?

ផាន ៖ ទៅវត្តបួស ។ វត្តនៅឯត្បូងនេះឯង ។

ប៊ុនថន ៖ នៅក្នុងភូមិនេះដែរ?

ផាន ៖ ទៅក៏ចូលវត្តបួសទៅ ដល់ទៅបួសរួច ។ បួសខែជេស្ឋ ដល់ខ្មែរក្រហមចូល មិនដឹងថាចូលខែ ណាទេរើយ ។ វាចូលអាខែមានទឹក ដូចថាខែជេស្ឋ ខែអាសាធ អីនោះឯង ។ បួសបានមួយបន្តិចក៏ ខ្មែរក្រហមវាចូល ។

ប៊ុនថន ៖ បានប៉ុន្មានវស្សាពូ?

ផាន ៖ មិនទាន់បានមួយវស្សាទេ ។ (សើច) ខ្មែរក្រហមចូលពេញភូមិនេះហើយ ។

ប៊ុនថន ៖ បាទ ។!

ផាន ៖ វាចូលពេញភូមិតាវងនេះឯង ។

ប៊ុនថន ៖ កាលបួសនៅវត្តបុស្សហ្នឹង..

ផាន ៖ វត្តតាវង ។

ប៊ុនថន ៖ កាលនោះគេហៅវត្តតាវង?

ផាន ៖ បាទ វត្តតាវង ។ វត្តភូមិនេះឯង គឺវត្តតាវង ។

ប៊ុនថន ៖ កាលបួសហ្នឹង លោកមានច្រើនទេ?

ផាន ៖ ច្រើន ។

ប៊ុនថន ៖ ប៉ុន្មានអង្គពូ?

ផាន ៖ ជាងសាមសិបអង្គជាង ។

ប៊ុនថន ៖ ជាងសាមសិបអង្គ, បាទ ។ ហើយកាលនោះ សង្ឃរាជវត្តពីណាគេវិញពូ?

ផាន ៖ គេជ្យគុណ ពូន ។

ប៊ុនថន ៖ គេជ្យគុណ ពូន ។ កាលនោះ ព្រះអង្គគាត់ចាស់វស្សា ឬមួយក៏ក្មេង ។

ផាន ៖ ព្រះអង្គសង្កត់បាត់ហើយ ។ លោកបួសតាំងពីដើម តាំងពីក្មេងមក ។ ដល់សម័យបីឆ្នាំគេឲ្យគាត់សឹក ដល់ពេលអញ្ចឹងទៅ គេបង្កើតលោកទៀត គាត់ក៏បួសទៀត ។ ទាល់តែលោកសង្កត់ចាស់ ។

ប៊ុនថន ៖ អញ្ចឹងនៅពេលខ្មែរក្រហមចូលមកហ្នឹង ពូកំពុងតែបួសទេ?

ផាន ៖ បាទ កំពុងតែបួស ។

ប៊ុនថន ៖ ពេលចូលមកដល់ភូមនោះ គេម៉េចដែរពូ?

ផាន ៖ គេគៀងយើង ។ ដល់គៀងអញ្ចឹងទៅ អាអ្នកទៅជាមួយក៏បានទៅ អាអ្នកមិនបានទៅក៏នៅក្នុងភូមិនេះហើយ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដល់ស្រាប់តែដល់ខែក្រោយ ថ្ងៃក្រោយ វាចូលមកទៀត ។ ដល់ចូលយូរៗ វានៅជាប់ ។ ដល់ពេលអញ្ចឹងទៅ វាដេញទាហាន លន់ នល់ ចេញទៅ វានៅក្នុងភូមិនេះជាប់ ។ ដល់ពេលដែលទាហានក្នុងស្រុកនេះឡើងមកម្តងៗ បាញ់គ្នាទៅវិញទៅមក ។ ដល់យូរទៅ អត់ហ៊ាននៅក្នុងភូមិ ក៏ខ្មែរក្រហមគៀងទៅនៅក្នុងព្រៃ ទាំងលោក ទាំងអ្នកស្រុក ។ (សើច)

ប៊ុនថន ៖ ឆ្នាំប៉ុន្មានពូកាលនោះ ពេលខ្មែរក្រហមគៀងនោះ?

ផាន ៖ ឆ្នាំ៧៣? បើសន្តិភាពឆ្នាំ៧៥ ។ នោះហើយឆ្នាំ៧៣ ។

ប៊ុនថន ៖ គៀងតាំងពី៧៣ណ៎ាពូ?

ផាន ៖ ទេ បើមិន៧៣ទេ ៧៤ ព្រោះ៧៥សន្តិភាព ។ ដូចថារស់នៅក្នុងព្រៃបានមួយឆ្នាំ ក៏សន្តិភាព ។

ប៊ុនថន ៖ ចុះពូ ពេលគេគៀងទៅហ្នឹង ពូនៅតែជាព្រះសង្ឃដែលអី?

ផាន ៖ នៅលោក ។

ប៊ុនថន ៖ ចុះគេគៀងធ្វើម៉េច?

ផាន ៖ ទៅនៅធ្វើជំរុំ នៅជាមួយប្រជាជននោះឯង ។

ប៊ុនថន ៖ ប៉ុន្តែ យើងនៅពាក់ស្បង់ ពាក់អីដដែល?

ផាន ៖ បាទ ពាក់ស្បង់ពាក់អីដដែល ។ ធ្វើកន្លែងនោះផ្សេង ធ្វើកម្រោងនោះផ្សេងទៅ ។ នៅឆាន់ជាមួយគ្នាលោកៗ ប៉ុន្មាននាក់នោះឯង ។

ប៊ុនថន ៖ កាលនោះប៉ុន្មានអង្គ?

ផាន ៖ ដល់ពេលលោករត់ទៅ ក៏សឹក ។ គេសឹកច្រើនណាស់ លោកនោះណា ។ កាលនោះលោកប្រហែលជាដប់អង្គប៉ុណ្ណោះឯង ។

ប៊ុនថន ៖ ដប់អង្គទេ?

ផាន ៈ បាទ ស៊ីកទៅតាមញ៉ាមទៅតាមអីអស់ ដោយសារតែស្រុកវាលំបាកអញ្ចឹងណា ។ ហើយនៅតែពួកខ្ញុំប៉ុណ្ណោះឯងដែលម៉ែមិនឲ្យស៊ីក ព្រោះស៊ីកទៅ ពួកឈ្លបគេឲ្យធ្វើខ្មែរក្រហម ។ ដល់អញ្ចឹងហើយ ក៏អត់ស៊ីក ។

ប៊ុនថន ៈ អញ្ចឹងយើងនៅតែជាលោកដដែល?

ផាន ៈ នោះឯងនៅតែជាលោក ។

ប៊ុនថន ៈ ចុះសង្ឃរាជវត្ត លោកទៅជាមួយទេ?

ផាន ៈ សង្ឃរាជលោកគាត់ទៅបាត់ដំបងទៅអី អត់នៅជាមួយទេ ។ មុនដំបូងលោកនិមន្តមក ថ្មពួក ហើយទៅមិនដឹងថាលោកនិមន្តទៅណាទេ ។ រហូតដល់សន្តិភាព លោកក៏និមន្តមកត្រពាំងថ្ម រួចហើយពួកខ្ញុំក៏ទៅនិមន្តលោកមកវិញ ។ កាលណោះនៅតែជាមួយគ្រូសូត្រ ។

ប៊ុនថន ៈ គ្រូសូត្រហ្នឹងឈ្មោះអ្វីពូ?

ផាន ៈ គ្រូសូត្រកាលណោះឈ្មោះ គ្រូធំ ។

ប៊ុនថន ៈ ឈ្មោះគ្រូធំ ។ អញ្ចឹងគាត់ក៏ត្រូវជន្លៀសទៅជាមួយខ្មែរក្រហមដែរ?

ផាន ៈ បាទ, កាលណោះទៅនៅព្រៃ ។

ប៊ុនថន ៈ ចុះចង្ហាន់បានមកពីណា បើនៅក្នុងព្រៃអីចឹង?

ផាន ៈ ចង្ហាន់បានពីអ្នកស្រុក ។ ព្រោះនៅសល់តែលោកតិច ក៏អ្នកស្រុកចេះតែជួយ ។ កាលណោះក៏បានដាំសណ្តែកផង ។ ដល់ពេលអ្នកស្រុករត់ទៅនៅវាលទៅវិញទៅមក ពួកខ្ញុំកាលដែលនៅជាលោកនៅសម័យនោះ ដាំតែខ្លួនឯង ។

ប៊ុនថន ៈ ដាំអីវិញពូ?

ផាន ៈ ដាំចង្ហាន់ដាំបាយ ។ ប៉ុន្តែកាលណោះម្ហូបអត់មានទេ ។ ប៉ះថ្ងៃណានោះមានតែបុក អា សន គេជួយបុកនោះ បុកតែគ្រឿងសុទ្ធ មានតែល្មៀត ម្ទេញប៉ុណ្ណោះឯង ពីព្រោះវាផ្អើលខ្លាចទាហាន ក៏ព្រឹកឡើងដាំបាយពីព្រឹក ឆាន់ហើយ ក៏នាំគ្នាទៅពួននៅក្នុងព្រៃឯណ៉ា ។

ប៊ុនថន ៈ ខ្លាចអីពូ?

ផាន ៈ ខ្លាចពួកទាហាន ។

ប៊ុនថន ៈ ពួកទាហានណា?

ផាន ៈ ពួកទាហាន លន់ នល់ ។ ហើយដល់ពេលខ្មែរក្រហមកាន់កាប់ ខ្លាច លន់ នល់ វិញ ។ តែកាលពេលខ្មែរក្រហមមិនទាន់កាន់កាប់ ខ្លាចខ្មែរក្រហមវិញ ។

ប៊ុនថន ៈ បាទ, អញ្ចឹងកាលពូនៅ នៅខាងខ្មែរក្រហមទេ ។

ផាន ៖ បាទ នៅខាងខ្មែរក្រហម ។

ប៊ុនថន ៖ ចុះកាលណោះ ជន្លៀសទៅភូមិណា កាលសម័យខ្មែរក្រហម?

ផាន ៖ ទៅក្នុងព្រៃ អត់មានភូមិទេ ។

ប៊ុនថន ៖ ព្រៃនៅឯណាដែរ?

ផាន ៖ ព្រៃទៅឯលិចភូមិឯណោះ

ប៊ុនថន ៖ ឆ្ងាយដែរពីភូមិនោះទៅ?

ផាន ៖ ឆ្ងាយពីភូមិនេះទៅ ប្រាំមួយទៅប្រាំពីរគីឡូ ជិតទៅដល់ភូមិគេឯណោះ ។

ប៊ុនថន ៖ ឥឡូវសព្វថ្ងៃគេហៅភូមិអី?

ផាន ៖ គេហៅ ព្រះលាន ។

ប៊ុនថន ៖ ជាភូមិអី?

ផាន ៖ នៅក្បែរត្រពាំងព្រលាន ។ អត់មានភូមិទេ ។ ប៉ុន្តែ ភូមិគេមាន តែវានៅឆ្ងាយពីត្រពាំង នោះ ។ មានភូមិដែរ ដែលគេហៅថាភូមិ ពួក ។ ពេលខ្ញុំទៅនៅឯណោះគឺនៅក្នុងព្រៃ ។ ទៅនៅក្នុងព្រៃ អត់មានអីទេគឺត្រូវដីក ត្រង់សេ សុទ្ធតែលូនកាត់ដំបូក ព្រោះខ្លាចកំប៉ាល់ ហោះ ។ កប៉ាល់តែថ្ងៃម៉ោងបីអីមកហើយ ដល់តែពេលព្រឹកអត់មានមកទេ ។ ដល់តែ ម៉ោងបី ម៉ោងបួនអីមកហើយ ។

ប៊ុនថន ៖ កប៉ាល់ហោះខាងណាពូ?

ផាន ៖ ខាង លន់ នល់ មកទម្លាក់ ។ ពេលខ្លះ ដូចខ្ញុំជាលោកកំពុងតែដើរទៅស្រង់ទឹកអញ្ចឹង ដូចថាទៅស្រង់ទឹកនៅឯអូរនៅក្នុងព្រៃអញ្ចឹងណា ។ នោះគេហៅ អូរយាង ។ ឧបមាថា អានេះវាលអញ្ចឹង ពេលកប៉ាល់ហោះមក អង្គុយនៅនោះឯង អត់ហ៊ានរត់ទេ ។ បើយើង រត់ កប៉ាល់ទម្លាក់ ព្រោះគេថាយើងខ្មាំង ។ អត់ហ៊ានរត់ ។ តែឯងរត់ កប៉ាល់ហោះគេ ទម្លាក់ថាយើងខ្មាំង ។ នោះហើយសម័យខ្មែរក្រហម ។ងៃ

ប៊ុនថន ៖ បាទ ចុះមានដែរទម្លាក់ទេ? .

ផាន ៖ មាន ។ មានទម្លាក់ចំតែឯភ្នំ ទន្លេឯណោះ ។ នៅឯភូមិ ទន្លេ ។ មួងនោះ ខ្ញុំទៅអូរ ស្រាប់ តែកប៉ាល់ហោះគេមកដល់ដែរ អូភ័យណាស់ ។ ក្រាបត្រង់នេះមិនហើយ ត្រង់នោះមិន ហើយ ។ (សើច) ។ អាប្រាំងអូរហើយ នៅតែភ័យទៀត ព្រោះវាឆ្អែលនៅតែពីលើ កប៉ាល់ហោះពីរ ។ ដល់ពេលវាទម្លាក់ វាបន្ទាបខ្លួនមកអញ្ចេះ ហើយឡើងទៅអញ្ចេះបាន

ធ្លាក់ៗ បើឃើញចុះក្បាលអញ្ចេះហើយ បានផ្អែលទៅណោះអត់ទម្លាក់ទេៗ ដល់ពេលឃើញទៅអញ្ចេះ ហើយឡើងអញ្ចេះបានទម្លាក់ៗ តែដល់ពេលអញ្ចេះអត់ទម្លាក់ទេៗ

ប៊ុនថន : ពេលលោកពូទៅ អត់ដែលប៉ះចំទម្លាក់ទេ?

ផាន : វាទម្លាក់តែខាងដើង ខាងដើងផុតឯណោះៗ តែបើផ្អែល ផ្អែលមកដល់យើងនេះហើយៗ ដល់ពេលទម្លាក់ វាទម្លាក់ទៅឯណោះផុតទៅៗ

ប៊ុនថន : ចុះនៅព្រៃអញ្ចឹង ធម៌អាអី នៅសូត្រធម្មតាតើអីពូ ដូចជាថ្ងៃសីល ថ្ងៃអីអញ្ចឹងណា?

ផាន : ទេ ដូចជាមិនសូវបានជាសូត្រប៉ុន្មានទេៗ ប៉ុន្តែដល់ពេលមានមនុស្សងាប់អីទៅ គេក៏និមន្តឲ្យសូត្រៗ ដោយសារតែមិនបាននៅវត្ត ក៏មិនបានថ្វាយបង្គំព្រះទេៗ បើនៅវត្តវិញថ្វាយបង្គំព្រះព្រឹកល្ងាចៗ ៗ

ប៊ុនថន : ចុះកាលណោះ នៅស្លៀកស្បង់ស្លៀកអីដូចមុនដែរលោកពូៗ

ផាន : នៅស្លៀកស្បង់ជីពរអីធម្មតាៗ

ប៊ុនថន : ចុះអ្នកភូមិអីទៅច្រើនដែរពូ?

ផាន : ទាំងអស់ មួយភូមិនេះៗ

ប៊ុនថន : ច្រើនទេ? ប៉ុន្មានរយនាក់?

ផាន : មិនដឹងប៉ុន្មានរយនាក់ទេៗ ដឹងតែមួយភូមិនេះឯងៗ

ប៊ុនថន : បាទ មួយភូមិតាវ៉ងនេះ?

ផាន : ក៏ប៉ុន្តែវាមិនច្រើនដូចសព្វថ្ងៃនេះទេណាៗ សព្វថ្ងៃវាកាត់តែច្រើនៗ

ប៊ុនថន : ចុះមានមេភូមិអីនៅលាយជាមួយពូទេ?

ផាន : អត់មានទេៗ ភូមិគេគឺនៅក្នុងព្រៃដែរៗ តែគេនៅក្នុងព្រៃដាច់ដោយឡែកពីគ្នាៗ

ប៊ុនថន : ចុះខាងគ្រប់គ្រងគឺខ្មែរក្រហមគ្រប់គ្រង?

ផាន : នោះឯងខ្មែរក្រហមៗ

ប៊ុនថន : មេឈ្មោមខ្មែរក្រហមអីពូ ឬមួយក៏កងទ័ព?

ផាន : ទេ គេមានកម្មាភិបាលគេៗ គេចាត់តាំងឲ្យធ្វើកម្មាភិបាលៗ

ប៊ុនថន : ហ្នឹងគ្រប់គ្រងដូចថាតាមភូមិអីពូ?

ផាន : នោះហើយ គ្រប់គ្រងតាមភូមិៗ ប៉ុន្តែ វាមិនសូវដែលបាននៅទេ ព្រោះវាទៅតែសមរភូមិមុខៗ វាមិនបាននៅវល់វឹកជាមួយប្រជាជនទេៗ

ប៊ុនថន : ចុះមានអ្នកណានៅក្នុងភូមិ តាវ៉ង ហ្នឹង? ទុកចោល ឬក៏ទាហាន លន់ នល់?

ផាន ៖ ទេ អត់មាននរណានៅទេ ។ ទុកចោល ។

ប៊ុនថន ៖ ចុះផ្ទះសម្បែងអី ទុកចោល?

ផាន ៖ ទុកចោល ។

ប៊ុនថន ៖ ចុះគោក្របីអី?

ផាន ៖ ទេ គោលក្របីអីយកទៅ បររទេះដឹកស្រូវដឹកអី យកទៅដាក់ក្នុងជុប ក្នុងព្រៃហ្នឹងឯង ។ ច្រកបាវទៅ ក៏ដាក់វានៅទន្នីរ ។

ប៊ុនថន ៖ បាទ អញ្ចឹងនៅក្នុងភូមិ ខាងខ្មែរក្រហមក៏អត់មាន ខាង លន់ នល់ ក៏អត់មានដែរ ។

ផាន ៖ ប៉ុន្តែខ្មែរក្រហមនៅភូមិនេះ តែវាដើរធ្វើការ វាមិននៅជាប់នៅភូមិទេ ។ វាដើរធ្វើការ ទាហាននៅត្រពាំងថ្ម វាដើរទៅមករកគ្នា ។ ដូចថាអ្នកឯនេះគេឃាម អ្នកនោះគេឡើងមក ធ្វើការណា ។

ប៊ុនថន ៖ ខាងត្រពាំងថ្មក៏ខ្មែរក្រហមដែរ?

ផាន ៖ ទេ ទាហាន លន់ ណុល ។

ប៊ុនថន ៖ តែខាងនេះ ខាងខ្មែរក្រហម ។

ផាន ៖ បាទ ខាងនេះគេខ្មែរក្រហម គេធ្វើការឃាមល្បាត ។ ដល់ពេលសន្តិភាពទៅ បានគេឲ្យខ្ញុំ សឹក នោះទើបលោកសឹក ។ វាឲ្យលោកសឹក សម័យនោះវាមានវត្តឯណា ។ វាដេញ លោកសឹកអស់ ។

ប៊ុនថន ៖ ដល់សន្តិភាពទៅ ពូទៅឯណា?

ផាន ៖ មកភូមិវិញ ។

ប៊ុនថន ៖ និមន្តមកភូមិវិញ ។

ផាន ៖ មកភូមិវិញមិនដល់មួយឆ្នាំទេ ។

ប៊ុនថន ៖ ចូល៧៦នៅពូ?

ផាន ៖ សន្តិភាពនៅ៧៥ ហើយក៏មកនៅវត្តវិញ ។

ប៊ុនថន ៖ បានប៉ុន្មានខែគេដេញ?

ផាន ៖ បានយូរគ្រាន់ ។ វាបានបួនប្រាំ ប្រាំមួយខែ ។ វាយូរគ្រាន់ហ្នឹងឯង ទើបបានវាដេញឲ្យ លោកសឹក ។

ប៊ុនថន ៖ វាដេញថាម៉េចពូ?

ផាន ៖ វាមិនឲ្យមានវត្ត ។

ប៊ុនថន ៖ គេថាម៉េចវិញ?

ផាន ៖ គេថាវាមិនឲ្យមានវត្ត ។

ប៊ុនថន ៖ គេនិយាយជាមួយយើងស្រួល ឬក៏យ៉ាងម៉េច?

ផាន ៖ វាគ្រាន់តែមកនិយាយថា វាមិនឲ្យមានលោក មានអី ។ វាប្រាប់តាមកម្មាភិបាល អ្នកស្រុក ទៅអីទៅណា ហើយគេមកប្រាប់លោក ។

ប៊ុនថន ៖ កាលណោះនរណាជាកម្មាភិបាល? គាត់ឈ្មោះអី ពូមានចាំទេ?

ផាន ៖ មិនបានចាំទេ ព្រោះកម្មាភិបាលច្រើនណាស់ ។ វាច្រើនណា ដូចថាមានកម្មាភិបាលចាត់តាំងផង ហើយក្រុមវាផងទៅ ។

ប៊ុនថន ៖ បាទ ដូចថាគេអ្នកដឹកនាំភូមិ គេចាត់តាំង?

ផាន ៖ កាលណោះអត់ទាន់មានទេ ព្រោះជាជំនាន់សន្តិភាព ។ ក្រោយមកទើបមានប្រធានកង ប្រធានអី ។ កាលណោះ មានភូមិនេះ ដូចថាចូលធ្វើយោធា ។ អាណោះមាន ។ តែបើថាឲ្យមានកម្មាភិបាល អត់ទាន់មានទេ ។

ប៊ុនថន ៖ ខ្ញុំទៅផុត ។ ដល់ពេលឈប់បួសទៅ ខ្ញុំទៅចល័តបាត់ទៅ ។

ផាន ៖ ដល់ពេលគេឲ្យសឹក គេនិយាយស្រួលតើអីពូ?

ប៊ុនថន ៖ និយាយស្រួល ។ តែបើយើងមិនព្រមសឹក គេមានវិធានការចាត់ចែង ។ បើយើងរឹង គេវាយយើងចោល ។

ផាន ៖ អញ្ចឹងពេលគេប្រាប់ថាសឹក សឹកទាំងអស់អញ្ចឹងទៅ ។

ប៊ុនថន ៖ អត់មាននរណាគេនៅស្តាយអីទេពូ?

ផាន ៖ អត់មានទេ ។ បើទោះបីជាស្តាយ ក៏ត្រូវតែសឹក ។

ប៊ុនថន ៖ ចុះសង្ឃរាជ?

ផាន ៖ សង្ឃរាជ សឹកដែរ ។ ខ្ញុំសឹកមុនបានបីថ្ងៃហើយ លោកក៏សឹកក្រោយ ។ គេអត់ឲ្យមានលោក មានវត្តអីទេ ។

ប៊ុនថន ៖ ចុះពេលសឹកហើយ ធ្វើអីវិញពូ?

ផាន ៖ អត់មានធ្វើទេ ។ គ្រាន់តែដើរចល័ត ដើរតាមវត្ត តាមកុដលោកអីទៅ ។ កាលណោះខ្ញុំចល័តបានយូរគ្រាន់ដែរ ។ តែដល់ពេលគេរើសខ្ញុំទៅ បានខ្ញុំទៅ ។ កាលណោះក្នុងមួយភូមិ គេរើសប្រាំនាក់ ។ រើសប្រាំនាក់សម្រាប់ឃុំណា ក្នុងមួយស្រុក ។

ប៊ុនថន ៖ មួយភូមិប្រាំនាក់?

ផាន ៖ ទេ មួយឃុំ ។ មួយឃុំប្រាំនាក់ក្នុងមួយស្រុក ។ គេយកមួយឃុំប្រាំនាក់ៗ ឲ្យទៅជួបគ្នានៅឯស្រុក ឡើងឡានអីទៅណា ។

ប៊ុនថន ៖ ខាងណាគេជ្រើសរើសកាលណោះពូ?

ផាន ៖ ខាងភ្នំស្រុក ។

ប៊ុនថន ៖ ខាងណាពូ? ដូចថាអ្នកណាគេជាអ្នកជ្រើសរើសេ?

ផាន ៖ អ៊ី ខាងខ្មែរក្រហម ។ កាលណោះគឺវាសន្តិភាពខ្មែរក្រហម ដូចថាខ្មែរក្រហមកាន់ក្តាប់ហើយណា ។

ប៊ុនថន ៖ បាទ ខាងភ្នំស្រុក ។ កាលណោះឯភ្នំស្រុក អ្នកណាគេជាអ្នកគ្រប់គ្រងពូ?

ផាន ៖ ខ្មែរក្រហម កាលណោះថ្នាក់ស្រុក តា ហាត់ ជាអ្នកមុនដំបូង ។

ប៊ុនថន ៖ គេហៅគាត់តា ហាត់ៗ អញ្ចឹងតែម្តងពូ?

ផាន ៖ នោះឯង ។ ប៉ុន្តែជីតាគាត់ដឹងណាគេទេ ។

ប៊ុនថន ៖ ឈ្មោះជីតាគាត់អី? ត្រកូលអីគេ?

ផាន ៖ ត្រកូលគាត់មិនដឹងអីទេ ។ ខ្ញុំវាតូចតាចមិនដឹងអីទេ ។

ប៊ុនថន ៖ តា ហាត់ ហ្នឹងដំបូងធ្វើអីគេវិញ?

ផាន ៖ គាត់ជាគណៈស្រុក ។

ប៊ុនថន ៖ គណៈស្រុកតាំងពីសម័យតស៊ូអីពូ?

ផាន ៖ ទេ គណៈស្រុកកាលសម័យខ្មែរក្រហមសន្តិភាព ។ ដល់ក្រោយមក គាត់ត្រូវគេវាយចោលដែរ នៅពេលនិរតីចូលមក ពេលនោះពួកនិរតីចូលមកធ្វើម្តង ។

ប៊ុនថន ៖ គាត់អ្នកស្រុកអី?

ផាន ៖ មិនដឹងថាស្រុកណាទេ ។ ខ្ញុំមិនដឹងស្រុកកំណើតគាត់ទេ ប៉ុន្តែគាត់និយាយធម្មតា ដូចខ្ញុំអញ្ចឹងឯង ។

ប៊ុនថន ៖ ហើយពូ ពេលគេរើសប្រាំនាក់ហ្នឹង ពូបានចូលដែរ?

ផាន ៖ ចូលគេដែរ ។

ប៊ុនថន ៖ ពីណាខ្លះ គ្នាប្រាំនាក់ហ្នឹង អ្នកភូមិអីមានចាំទេ?

ផាន ៖ កាលណោះមានតែខ្ញុំ អាយៀត មកពីស្វាយខ្មៅ និង អា...

ប៊ុនថន ៖ ឈ្មោះអី? យៀតអី?

ផាន ៖ ឈ្មោះអា យៀត មកពីស្វាយខ្មៅ, អាឈឹតមួយ ៗ អាឈឹតនោះស្លាប់បាត់ហើយមើលទៅ បាត់មិនឃើញមកផ្ទះទេ ។

ប៊ុនថន ៖ តា យៀត ហ្នឹងនៅរស់តើអីសព្វថ្ងៃនេះ?

ផាន ៖ បាទ នៅរស់ ៗ ប៉ុន្តែ អាយៀតនេះ មិនសូវនៅផ្ទះទេ ៗ វាចេះតែទៅរកស៊ីនៅថ្មពួក ៗ ហើយ អា យឿន នោះមួយ ៗ អា យឿន នោះស្លាប់ហើយ ព្រោះវាធ្វើទាហាន ៗ

ប៊ុនថន ៖ ហើយពីណាគេទៀត?

ផាន ៖ មិនដឹងអាណាគេអញ្ចេះមួយទៀត ៗ ភ្លេចបាត់ហើយ ៗ អូ អា ឆាវ ៗ អា ឆាវ ភូមិខ្ញុំនេះស្លាប់ដែរ ព្រោះកាលដែលសម័យខ្មែរក្រហមចូលមក ក៏បាត់មិនឃើញមកផ្ទះ ៗ ដល់ពេលដែលអាគ្នារបស់ខ្ញុំដែលធ្វើជាខ្មែរក្រហមនោះ ដល់យួនចូលមកក៏វារត់ចូលទៅក្នុងព្រៃចូលមកភូមិនេះហើយក៏ខ្ញុំឃើញ ក៏ស្គាល់ ហើយទៅក៏សួរវា ហើយវាថាអា ឆាវស្លាប់ហើយ ព្រោះយួន បាញ់ត្រូវ ៗ វាប្រាប់ទាំងភូមិ តែខ្ញុំភ្លេចទៅ ៗ

ប៊ុនថន ៖ បាទ!

ផាន ៖ ប្រាំនាក់ទៅ ហើយក៏ជុំជួបគ្នា ឡើងឡានទៅភ្នំស្រុកនោះឯង ហើយក៏នៅស្វាយបានប្រាំពីរថ្ងៃ ក៏គេមិនឲ្យធ្វើអីទេ ៗ ស៊ីតែបាយ ដេក ៗ (សើច)

ប៊ុនថន ៖ នៅមុំណា នៅស្វាយនោះពូ?

ផាន ៖ នៅក្នុងផ្ទះថ្មគេមួយ អាផ្ទះថ្មចាស់ពីបុរាណនោះណា ៗ អាជួរផ្ទះថ្មពីដើមមិញ វាមានបីជាន់ទៅអញ្ចេះទៅ ហើយទទឹងមកអញ្ចេះ កាត់ទទឹងថ្ងៃ ៗ

ប៊ុនថន ៖ តាមផ្លូវទៅណាពូ ផ្លូវមក?

ផាន ៖ កាលណោះអត់មានផ្លូវទេ អត់មានជិតផ្លូវទេ ៗ

ប៊ុនថន ៖ ជិតផ្សារ ឬជិតបេនឡានអីទេ?

ផាន ៖ បើផ្សារគឺផ្សារសិរីសោភ័ណ្ឌនេះឯង ៗ ផ្ទះថ្មតាមនោះឯង ៗ តែកាលសម័យនោះ អត់ដែរមានមនុស្សនៅទេតាមផ្ទះថ្មនៅតាមនោះឯង ៗ

ប៊ុនថន ៖ តែពេលនោះពូជិះឡានទៅ?

ផាន ៖ នោះហើយជិះឡានទៅ ៗ

ប៊ុនថន ៖ គេដឹកទៅ? ច្រើនគ្នាទេកាលណោះពូ?

ផាន ៖ គ្រប់ឃុំ ៗ ក្នុងមួយស្រុកមានប៉ុន្មានឃុំ ទៅទាំងអស់ ៗ

ប៊ុនថន ៖ នៅស្រុកភ្នំស្រុកយើងហ្នឹងអីពូ?

ផាន :	នោះហើយ គ្រប់ឃុំ ។ មានប៉ុន្មានឃុំ ទៅទាំងអស់ ។ មួយឃុំប្រាំនាក់ៗ

ប៊ុនថន :	ហើយដឹកតាមឡានទៅ?

ផាន :	នោះហើយ ។ ទៅនៅស្វាយបានប្រាំពីរថ្ងៃ បានពេលល្ងាចឡើង គេដើរមកហៅ ហើយពួកខ្ញុំក៏ដើរតាមគេទៅ ។ គេសួរថា "មាននរណាចេះបើកអាត្រាក់ទេ?" មិនដឹងអីទេណា គេឲ្យបើកអាត្រាក់ ។

ប៊ុនថន :	បាទ!

ផាន :	អត់ឲ្យធ្វើអីទេ តែអត់មាននរណាចេះទេកាលសម័យនោះ ។

ប៊ុនថន :	អត់ចេះអញ្ចឹងធ្វើម៉េចទៅពូ?

ផាន :	រៀន ព្រោះមានគេអ្នកចេះមុនបន្ទាប់យើងតែមួយថ្ងៃចេះហើយ ។

ប៊ុនថន :	បាទ អញ្ចឹងពូរៀន បានចេះបើកនៅឯនោះទៅ?

ផាន :	ខ្ញុំបើករហូតដល់សម័យវៀតណាមចូល ។

ប៊ុនថន :	ប៉ុន្មានពូ? អាត្រាក់ច្រើនទេ?

ផាន :	អាត្រាក់ច្រើនតើ ។ មុនដំបូងអាត្រាក់៦០ដាក់ទុកភ្ជួរ សាលាក្រហម ។

ប៊ុនថន :	ឥឡូវសាលាក្រហមហ្នឹង គេនៅហៅសាលាក្រហមដដែលតើអីពូ?

ផាន :	ប្រហែលជាគេនៅហៅសាលាក្រហមដដែលហ្នឹង អាសាលាក្រហមផ្លូវទៅសំរោង អាផ្លូវចេញទៅអូរអំបិល ។

ប៊ុនថន :	បាទ ។ ពូទៅរៀននៅហ្នឹង?

ផាន :	ទៅភ្ជួរនៅហ្នឹង ។ មុនដំបូងគេឲ្យភ្ជួរនៅឯណោះឯង នៅសាលាក្រហមផង នៅកំបោលផង ស្រេចតែតាមគេតម្រូវ ឲ្យទៅណា ទៅណោះឯង ។

ប៊ុនថន :	ទៅណាខ្លះពូ?

ផាន :	សម័យនោះអាស្រ័យហ្នឹងគេដាក់ទិសដៅ ។

ប៊ុនថន :	ទៅភ្ជួរនៅម្ដុំណាខ្លះពូ? នៅសំរោង?

ផាន :	ទេ នៅសាលាក្រហមក៏ភ្ជួរ នៅកំបោលខាងក្រោមនោះក៏ភ្ជួរ នៅឯភ្នំកំបោលឯណោះ ។

ប៊ុនថន :	ភ្នំកំបោល ។

ផាន :	ពួកខ្ញុំធ្វើអីស្រេចតែតាមគេហៅ ។ គេឲ្យទៅណា ក៏ទៅនោះ ។

ប៊ុនថន :	ពូភ្នំកំបោលនោះ គឺភ្នំកំបោលស្រះហ្នឹងអីពូ?

ផាន ៖ នោះឯង ។ ភ្នំកំបោលស្រែះនោះឯង ។ សម័យដែលគេឡើកទំនប់រួច ក៏គេលេងសិល្បះ ។ គេនាំសិល្បះទៅលេង នៅភ្នំកំបោលនោះឯង ។ ពួក ឆវីន អីទៅលេង ។

ប៊ុនថន ៖ អ្ហ៎! ឆោម ឆវីន អីពូ?

ផាន ៖ នោះហើយ ។ កាលណោះ ឆោម ឆវីន អីនៅតូចៗ ។

ប៊ុនថន ៖ កាលណោះពូនៅស្គាល់ដែរ?

ផាន ៖ ស្គាល់ ។ កាលណោះនៅតូចៗប៉ុណ្ណោះឯង ។ បើរឿងច្រៀង គេថាមួយខេត្តនោះដាច់គេ ហើយបានទាំងកាយវិការទៀត ។ ពួកខ្ញុំមើលសិល្បះពួកវានោះឯង ។ បណ្ដោយដប់បីគីឡូម៉ែត្រ ភ្នំត្រដែតខ្ពស់កន្លង ជីវិតយើងពិតតែសោមន្សផង ។

ប៊ុនថន ៖ អ្ហ៎! នៅចាំដែរពូ?

ផាន ៖ ចាំតិចៗ ពេលគេច្រៀង ខ្ញុំនៅក្នុងក្បែរនោះឯង ។ ដល់ពេលចប់បានគេលេង ពេលគេឡើងទំនប់រួចហ្នឹងណាចាប់ពីកំបោល មកស្រែះ ។ រួចបានគេលេងសិល្បះឲ្យមើល ។

ប៊ុនថន ៖ ឆោម ឆវីនហ្នឹង?

ផាន ៖ ឆោម ឆវីនហ្នឹងជាអ្នកសិល្បះសម័យបីឆ្នាំ ។

ប៊ុនថន ៖ អ្នកសិល្បះខាងណាវិញពូ?

ផាន ៖ ខាងបន្ទាយមានជ័យនេះឯង ។

ប៊ុនថន ៖ ខាងបន្ទាយមានជ័យ ។

ផាន ៖ ឲ្យតែសិល្បះ មិនដែលអត់វាទេ ព្រោះវាជាអ្នកចំណានជាងគេខាងសិល្បះ កាយវិការ ។ កាលណោះវានៅតូចៗ ប៉ុនណេះឯង ។

ប៊ុនថន ៖ ច្រៀងពិរោះជាងគេ?

ផាន ៖ ចុះកាលណោះមិនទាន់មានអ្នកចម្រៀងអី ។

ប៊ុនថន ៖ ចុះថាមានប៉ុន្មាននាក់ពេលសម្ដែងម្ដងៗ?

ផាន ៖ មិនដឹងថាប៉ុន្មាននាក់ទេ ។ ដឹងថាច្រើនគ្រាន់ គេលេងតែគ្នាគេប៉ុន្មាននាក់នោះឯង ។

ប៊ុនថន ៖ ក្រៅពីគាត់ មាននរណាគេច្រៀងពិរោះទៀតទេ?

ផាន ៖ ទេ មិនសូវមានទេស្រី ឃើញមានតែវាមួយនោះឯង ។

ប៊ុនថន ៖ គេប្រកាសឈ្មោះអីបានជាពូដឹងថាជា ឆោម ឆវីន?

ផាន ៖ ទេ វានៅស្វាយ ។ ខ្ញុំក៏នៅនោះដែរ ។

ប៊ុនថន ៖ នៅស្វាយដែរ ។ ខាងសិល្បះគេនៅស្វាយ?

ផាន ៖ នៅស្វាយ ។ ខ្ញុំក៏នៅនោះដែរ ។

ប៊ុនថន ៖ គេហៅសិល្បៈអីវិញ? សិល្បៈស្រុក ឬតំបន់? គេហៅសិល្បៈអីវិញ?

ផាន ៖ ស្វាយពីដើមមិញគេហៅថាតំបន់ ។ វាជាតំបន់៥ ។ បើខាងសៀមរាបតំបន់ខាងណោះគេហៅតំបន់៦ ។ បើខាងមណ្ឌលបុរីឯណោះគេហៅតំបន់៣ ។

ប៊ុនថន ៖ ភ្នំស្រុកនេះតំបន់ប៉ុន្មានពូ?

ផាន ៖ តំបន់៥ដូចគ្នា ។ និយាយទៅ មួយខេត្តគេហៅមួយតំបន់ ។

ប៊ុនថន ៖ ចុះខាងសិល្បៈនៅក្បែរតំបន់ពូនៅដែរអី?

ផាន ៖ ទេ អត់ជាប់ទេ ។ គេនៅផ្ទះផ្សេងគ្នា ។

ប៊ុនថន ៖ នៅផ្សេងៗគ្នា ។ តែនៅជិតគ្នាដែរទេពូ?

ផាន ៖ ជិតគ្នាប្រហែលមួយគីឡូ ។ ខ្ញុំនៅតែត្រពាស ម្តងទៅនៅនេះ ម្តងទៅនៅនោះ ។ តែពួកសិល្បៈគេនៅស្វាយ អាផ្លូវចេញមកសៀមរាប ។ តាមផ្ទះមួយជួរនោះឯង ។ ពួកខ្ញុំនៅឯវត្តស្វាយ ។

ប៊ុនថន ៖ ច្រើនទេអ្នកសិល្បៈគេ ។ សុទ្ធតែស្រីៗទាំងអស់ឬមួយក៏ម៉េចពូ?

ផាន ៖ ប្រុសចង់ច្រើនជាងស្រី ។

ប៊ុនថន ៖ ក្រុមសិល្បៈគេនរណាជាអ្នកដឹកនាំ?

ផាន ៖ មិនដឹងទេ ។ ប៉ុន្តែ ពូថា ឆវីន នោះមានឪឈ្មោះ សារិន ថន ។ មិនដឹងថាឪវាជាអ្នកដឹកនាំក៏មិនដឹង ។ ឪវាហ្នឹងជាអ្នកលេងអាយ៉ៃ ក៏មិនសូវដឹង ។ ពូតែគេថា ។ ដោយសារតែយើងមិននៅជុំគេ ក៏មិនថានរណាជាអ្នកដឹកនាំ ។

ប៊ុនថន ៖ ពូពេលនៅបើកអាត្រាក់ នរណាជាអ្នកដឹកនាំពូ?

ផាន ៖ ប្រធានធំជាងគេឈ្មោះ ចយ ។

ប៊ុនថន ៖ ពូទៅនៅស្វាយហ្នឹងពីណាដូចថាប្រធានដឹកនាំកងអាត្រាក់ហ្នឹងពូ?

ផាន ៖ អ្ហ៎! ប្រធានធំជាងគេ ចយ ។

ប៊ុនថន ៖ ឈ្មោះ ចយ?

ផាន ៖ ប្រធានកងខ្ញុំឈ្មោះតា នួយ ។

ប៊ុនថន ៖ តាអីគេ?

ផាន ៖ តានួយ ។ ប្រធានកងតានួយ ប្រធានរោងតា ចក់ ។

ប៊ុនថន ៖ បាទ! ហើយហ៎ី កងអាត្រាក់ហ្នឹងប៉ុន្មានទៅពូ?

ផាន ៖ ក្នុងម៉ាកងខ្ញុំសាមសិបនាក់ហ្នឹងហើយ ។

ប៊ុនថន ៖ សាមសិបនាក់?

ផាន ៖ ដូចថានៅក្នុងអង្គភាពរបស់ខ្ញុំវាពីរបីកង ។

ប៊ុនថន ៖ បាទ!

ផាន ៖ ហើយអង្គភាពដូចធំជាងគេគឺតាចយ ។

ប៊ុនថន ៖ បាទ! តាចយ ។

ផាន ៖ ប្រធានក្តាប់រោង ។

ប៊ុនថន ៖ បាទ! កាលហ្នឹងគេហៅកងអាត្រាក់ឬមួយកងដូចថាកងបន្តុបន្ទេិនផលអីចូ?

ផាន ៖ អង្គភាពសហជីព ។

ប៊ុនថន ៖ អង្គភាពសហជីព?

ផាន ៖ គេដកពីយោធា ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដូចពួកយោធាគេហៅមកឲ្យកាន់អាត្រាក់ ។ ប្រធានកងមានអី ហើយប្រធានកងមិនទាន់គេដកកាំភ្លើងអស់អីទេ ដកតែកូនក្រុមមានកាំភ្លើងអាកាម្នាក់មួយៗហ្នឹងហ្ន៎ ។

ប៊ុនថន ៖ បាទ!

ផាន ៖ អនុកងប្រធានកង ដូចថាប្រធានអី គេដកកាំភ្លើងអី ។

ប៊ុនថន ៖ ចុះនោះខុសៗអីនេះអីចូអី? ដូចថាគេហៅអង្គភាពសហជីពតែហ្នឹង ។

ផាន ៖ បាទ ។

ប៊ុនថន ៖ បាទ!

ផាន ៖ អង្គភាពសហជីពពីណាគេ ។

ប៊ុនថន ៖ បាទ! សហជីពតំបន់ឬសហជីពអីគេវិញ?

ផាន ៖ គឺសហជីពតំបន់ ។

ប៊ុនថន ៖ តំបន់៥អីថាចឹង?

ផាន ៖ បាទ ។

ប៊ុនថន ៖ បាទហើយតាចយហ្នឹងគាត់នៅណា?

ផាន ៖ អង្គភាពសហជីបប្រចាំអ៊ាំ ។

ប៊ុនថន ៖ ហើយតាចយហ្នឹងគាត់ប្រធានអង្គភាពសហជីពហ្នឹងអីចូ?

ផាន ៈ បាទ! គាត់ធំជាងគេ ។

ប៊ុនថន ៈ បាទ ។

ផាន ៈ ដល់ក្រោយមកគេចាប់គាត់អស់ដែល សម័យហ្នឹងគេចាប់ទាំងអស់គ្នា ហើយយកទៅវៃចោលទាំងអស់ ប៉ុន្មូច...។

ប៊ុនថន ៈ ប៉ុន្តែពីមុនតាចយហ្នឹងគាត់ធ្វើអីពូកាលមុន? ពូ?

ផាន ៈ ទេ! ពីដើមមិញគាត់មិនធ្វើអី គាត់ដូចជាប្រធានអីចឹង ពីដើមមិញដូចសង្គ្រាម គាត់ប្រធានខាងយោធា ហើយចូលក្រោយគេ ។

ប៊ុនថន ៈ បាទ!

ផាន ៈ ហើយខ្ញុំមានសន្តិភាពហើយខ្ញុំចូល ។

ប៊ុនថន ៈ បាទ ។

ផាន ៈ ដល់ចូលទៅឃើញតែគាត់ប្រធាន ។

ប៊ុនថន ៈ ចុះអាត្រាក់អីថ្មីៗ ទេពូ?

ផាន ៈ ទេ! អាត្រាក់តាំងពីសង្គម កាលពីសម័យលន់ នល់ ។

ប៊ុនថន ៈ របស់អីវិញពូ?

ផាន ៈ អាត្រាក់ពួថាមកពីអង់គ្លេស ។

ប៊ុនថន ៈ មកពីអង់គ្លេស?

ផាន ៈ គេហៅតាមរយ ដូចថាម៉ាស៊ីនម៉ារយទៅ អាហុក ។

ប៊ុនថន ៈ អាហុក?

ផាន ៈ អាហុកមួយរយនេះដូចថាម៉ាស៊ីនអាហុក ដូចថាម៉ាស៊ីនអាម៉ារយ ដូចថាម៉ាស៊ីនអាម៉ារយដូចម៉ាមួយរយហុកប្រាំ ។

ប៊ុនថន ៈ បាទ!

ផាន ៈ ដូចថាពុំមានអាត្រាក់ធំៗដូចសព្វថ្ងៃហ្នឹងទេ ហើយមិនដែលមានដំបូលទេ ហើយចង្កូតយាប់ៗជាងអាត្រាក់យើងសព្វថ្ងៃហ្នឹង ។ មិនមានចង្កូតបូមមិនមានអីទេ ។

ប៊ុនថន ៈ អត់មានចង្កូតបូមទេ?

ផាន ៈ ទេ! អាកែបពុំមានរ៉ឺស័រ ។ ហើយអ្នកបើកអាត្រាក់ពីសង្គមមិញច្រើនធ្លាក់ឈាមងាប់

ប៊ុនថន ៈ បាទ! វារលាក់?

ផាន ៈ រលាក់ ។

ប៊ុនថន ៖ បាទ!

ផាន ៖ បើថាអ្នកណាបើកឃើតហ្នឹង គឺមានមនុស្សល្អ ។

ប៊ុនថន ៖ បាទ ។

ផាន ៖ ប៉ុនថាសម័យបីឆ្នាំមនុស្សស្លាប់ ។

ប៊ុនថន ៖ ស្លាប់ដោយសារអីវិញ?

ផាន ៖ អឺ អាត្រាក់នេះធ្លាក់ឈាមហើយទៅដេកពេទ្យទៅ ដូចនៅសម័យនោះពុំមានថ្នាំណានៅសម័យនោះ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ស្លាប់?

ប៊ុនថន ៖ ពិបាកទេពេលបើកភ្លូរមកម្ដងច្រើន?

ផាន ៖ ហើយអាត្រាក់នោះមានផាលតែបីមិនដូចផាលយើងសព្វថ្ងៃទេ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ផាលបីដូចថាមានវិលដាច់ពីគ្នា បើអានេះផាលច្រើនចឹងប៉ុនតែដុំវាវិលជាប់គ្នា ។

ប៊ុនថន ៖ បាទ!

ផាន ៖ អានោះវិលរៀងខ្លួនដូចផាលគោយន្តចឹងណា៎ ។

ប៊ុនថន ៖ បាទ!

ផាន ៖ វិលវាដូចផាលគោយន្តវាវិលផ្សេងគ្នា ផាលបីប៉ុនវាដូចថាដីរីង ដូចអាត្រាក់យើងសព្វថ្ងៃវាមុត ផាលវាតែបី វាវិលរៀងខ្លួន ហើយអាតាណាក់ធំរាស់ពិបាកណាស់មិនដូចអាត្រាក់នៅសព្វថ្ងៃហ្នឹងទេ ហើយអាប៉ាណាស់វាតូចៗរឹតស្រួល ។

ប៊ុនថន ៖ បាទ!

ផាន ៖ អាត្រាក់ពីដើមមិញរាស់គោវាធ្លាក់ញ័រៗទៅ ដូចខ្ញុំធ្លាប់រាស់អាត្រាក់ពីសង្គមមិញដូចរាស់គោ ។

ប៊ុនថន ៖ លោកពូដូចពិបាកទេដូចការងាររភ្ជួរដូចថាអត់សូវយ៉ាប់ទេ?

ផាន ៖ ពួកខ្ញុំដូចថាវាមិនសូវយ៉ាប់ប៉ុន្មានទេ គ្រាន់តែថាបានបាយហូបឆ្អែត ។ គេបាយឲ្យបន្តិចបន្តួច ។

ប៊ុនថន ៖ បាទ!

ផាន ៖ គេឲ្យបាយតិចតួច ហើយឲ្យបាយហូបឆ្អែត ប៉ះទៅណាបបរខ្លះដែរទៅ ហើយអាណា ទៅគេបើកបបរចល័តមកអត់ដែរ ។ យើងហូបអស់តិច អត់ដែលហូបឆ្អែតទេ ។

ប៊ុនថន ៖ គេហូបជាមួយចល័តឬក៏យើងមានអគ្គភាព?

ផាន ៖ អគ្គភាព ដូចស្រុកចូលចេះទៅខបមាថាគ្នាខ្ញុំដប់នាក់ចឹងទៅឆ្នាំងមួយ ឆ្នាំងបាយ ឆ្នាំងសម្ល មួយទៅ ។

ប៊ុនថន ៖ បាទ!

ផាន ៖ អាចានបាយមិនមាន មានស្លាបព្រាដាក់ខោប៉ាវវ៉ាកលូកឆ្នាំងសម្ល ឆ្នាំងបាយលូក ។

ប៊ុនថន ៖ បាទ! បើជុំគ្នាទៅហូបម៉ាឆ្នាំងហ្នឹងហ្នង ។

ផាន ៖ ដល់យ៉ាប់ច្រើនតែប្រុសទៅ ហើយយូរទៅៗមិនមានទរណាទុកទេ ហើយចានបាយអី យូរទៅក៏បាត់អស់ សល់តែឆ្នាំងបាយ ។ ពេលទៅៗជាមួយគ្នាទៀត ។

ប៊ុនថន ៖ បាទ ហ៊ុំអឺពេលភ្លូរហត់អី មានពេលណាឈប់សម្រាកអីអត់?

ផាន ៖ នោះ សម្រាកមួយពីរនាក់ ពីរនាក់បីនាក់ អ្ហូ យប់ៗចឹងទៅយើងដេកតាមអាសនៈ ។

ប៊ុនថន ៖ បាទ!

ផាន ៖ យប់ក៏ភ្លូរដែល ។

ប៊ុនថន ៖ យប់ភ្លូរដែលលោកពូ?

ផាន ៖ ភ្លូរ ។

ប៊ុនថន ៖ មានភ្លើងមានអីដែរ?

ផាន ៖ មានដល់ក្រោយមកអាត្រាក់ ដល់នែអាត្រាក់ក្រសម័យក្រោយ អាសម័យដែលគេ យកគណៈតំបន់.. គេចាប់ទៅយកនិរតីមកមិនឲ្យទាក់ទងថៃ ។

ប៊ុនថន ៖ អត់ឲ្យទាក់ទងថៃ?

ផាន ៖ អត់ទាក់ទងថៃ ហើយអត់បាន...អាត្រាក់មកក្រ ។

ប៊ុនថន ៖ អ្ហូ!

ផាន ៖ ដល់ពេលអាត្រាក់មក...ដោះពីអាមួយយកទៅដាក់អាមួយ ហើយយូរទៅចង់អស់ អាត្រាក់ ។

ប៊ុនថន ៖ បាទ! កាលពីនៅហ្នឹងយើងទិញសម្ភារពីណា ទិញពីថៃ?

ផាន ៖ ថៃ យើងបានកៅស៊ូទៅ យើងយកទៅលក់នៅថៃ ។

ប៊ុនថន ៖ បាទ?

ផាន ៖ ដេកក្អាប់កៅស៊ូ មានខ្មែរយើងម៉ាចំនួននោះលីណោះ កាលដើមមិញហៅប៉ៅយប៉ែត ហៅអូរជ្រៅ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ហៅអូរជ្រៅឯណុងលីសែងហ្នឹង ។

ប៊ុនថន ៖ លីសែងអីគេវិញពូ?

ផាន ៖ លីសែងដូចថាខ្មែរយើងដឹកទៅលក់ឲ្យថៃ ប្រហុកដូចអី ប៉ុនរបស់ខ្មែរយើងវាថោកហ្នឹងណា ប៉ុនរបស់វាទិញមកថ្លៃហ្នឹងណាំ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ហើយយើងមានលុយថ្លៃ ។

ប៊ុនថន ៖ ចឹងមានរបស់ហ្នឹងយើងយកទៅដូរ?

ផាន ៖ យកទៅដូរ យកទៅដូរ ។

ប៊ុនថន ៖ លក់មិញបើអត់ចាយលុយផងហ្នឹងពូ?

ផាន ៖ គេគ្រាន់តែលក់ឲ្យវាទៅទិញរបស់វាមកវិញ

ប៊ុនថន ៖ បាទ! ចឹងក្រោយពីនេះមក?

ផាន ៖ ខ្ញុំមិន ព្ញពីនេះប៉ុនលឺតែអ្នកដែលនៅលីនៅនោះ ប៉ុនអ្នកដែលគេឲ្យឈប់លីចូលកងខ្ញុំហ្នឹងទៅ ។

ប៊ុនថន ៖ បាទ!

ផាន ៖ មានតាំងគ្រាប់ឈូក ជ័រកៅ ,សណ្តែកបាយ ប៉ុនជ័រកៅស៊ូលក់បានថ្លៃជាងគេ ។

ប៊ុនថន ៖ ជ័រកៅស៊ូរមានដែរ?

ផាន ៖ ហ្នឹងហើយជ័រកៅស៊ូមានថ្លៃជាងគេ កាលហ្នឹងទិញគ្រឿងអាត្រាក់មកទិញមានគ្រឿងឡានហ្នឹងអោយថ្មីៗហ្នឹងហើយ ដល់អាត្រាក់រាស់ឲ្យជាងគេមើល... គេក៏ស្នើពីប្រធាន មក ។

ប៊ុនថន ៖ ស្នើពីតានេះហ្នឹងអី?

ផាន ៖ តាចយ ។

ប៊ុនថន ៖ តាចយ?

ផាន : ដល់ពេលដែលនិរតីចូលមកក្ដាប់ចាប់គណៈតំបន់ ហើយដើរចាប់គាចយ គណៈតំបន់ដើរចាប់ម៉ាខ្មែរ ហ្នឹងអស់ រលីងហ្នឹងណា៎ អាបាបុលយោលទាំងខ្មែរ ចាប់អស់រលីង។ ដាក់ពួកវា ថ្មីទៀត។

ប៊ុនថន : បាទ!

ផាន : ហ្នឹងអត់ឲ្យចេញចូលថៃទេ បិទក្បិប ក្រចូល មិនឲ្យខ្មែរទេ។

ប៊ុនថន : កាលហ្នឹងឆ្នាំប៉ុន្មាន?

ផាន : កាលណុងប្រហែលឆ្នាំសិតសិបប្រាំពីរទៅ, ៧៨។

ប៊ុនថន : ៧៧? ៧៨?

ផាន : កាលណុងឆ្នាំ៧៦, កៀកចូល៧៧ហេយកៀកចូល៧៨។ មិនទាន់ដល់ជម្លៀស៧៨ទេណា៎ មិនទាន់ មានវៀតណាមចូលមកទេ។

ប៊ុនថន : កាលហ្នឹងចាប់ចូលគាចយមកហ្នឹងនៅ?

ផាន : ចាប់ ពួកអស់ហ្នឹងរួចមក ចាប់ហើយនិរតីដាក់គ្នាវា មកមិនឲ្យចេញចូលថៃក្រយោលឲ្យខ្មែរប្រឌិតខ្លួនឯង ឲ្យ ចាក់ប្រវ៉ាត់លីខ្លួនឯង។

ប៊ុនថន : អ្ហ៎?

ផាន : កាលណាចាក់ចូលរាយឆេះអស់ មិនធ្វើកើតណា៎។

ប៊ុនថន : ធ្វើបានខ្លួនឯង?

ផាន : ដោះមួយយកទៅដាក់មួយ។

ប៊ុនថន : បាទ!

ផាន : ហើយជួនកាលដោះពីរយកទៅដាក់មួយ។

ប៊ុនថន : បាទ!

ផាន : អារបស់ចាស់ជាងគេ។

ប៊ុនថន : ហើយគាហឹងអីពូស្គាល់ដែរ?

ផាន : ស្គាល់។

ប៊ុនថន : គាត់ៗអីវិញពូ? គណៈតំបន់?

ផាន : គណៈតំបន់។ គាហឹងសតើ គាត់ចិន ដូចប្អូនឯងហ្នឹង គាត់ចិនសមាំមានដូចមិនកូនអ្នកក្រតើ កូនអ្នកមាន។

ប៊ុនថន : គាត់អ្នកណាដែរ អ្នកស្រុកណាដែរ.?

ផាន :	ទេពុថា នៅបាត់ដំបង ប៉ុន្តែគាត់សដូចចិន ។

ប៊ុនថន :	គាត់ក្រៅពីឈ្មោះហ្នឹង មានឈ្មោះអីទៀតទេពូ?

ផាន :	អត់ដឹងទេ ខ្ញុំឮគេថាហៅតាហឹង ។

ប៊ុនថន :	ហើយពូខស្សាហ៍ជួបគាត់ដែរតើពូអី?

ផាន :	ទេ ខ្ញុំជួបកន្លែងសន្និបាត ។

ប៊ុនថន :	សន្និបាតនៅណា?

ផាន :	សន្និបាតនៅស្វាយណុង ។

ប៊ុនថន :	ស្វាយ? នៅម្តុំណាពូមានចាំទេរាល់ថ្ងៃ?

ផាន :	ម្តុំផ្លូវរហូតដល់សព្វថ្ងៃសៀមរាប ហើយដើមវិញអា ផ្លូវគេប៉ោយប៉ែតមក ហើយ
ផ្សារលើ ទៅចេះទៅមង្គលបុរីអីណុ៎ ។

ប៊ុនថន :	បាទ ។

ផាន :	ហើយ នៅជិតខាងត្បូង ។

ប៊ុនថន :	បាទ ខាងត្បូងហ្នឹង?

ផាន :	អាផ្លូវដូចថាយើងព្រហ្មសហើយដើរទៅខាងត្បូងជាប់ទៅផ្លូវមង្គលបុរីតែម្តង
រហូតអាផ្សារសេរីសោភ័ណខាងត្បូង ។

ប៊ុនថន :	អាផ្លូវកាត់អាត្រាក់អីហើយផ្លូវអាត្រាក់អីពូអី?

ផាន :	ផ្លូវថ្នល់ ។

ប៊ុនថន :	អ្ហ៊ូ! ផ្លូវរទេះភ្លើងអាម៉ាជួរផ្លូវ?

ផាន :	មិនទាន់ដល់ផ្លូវរទេះភ្លើងទេ ហើយផ្លូវរទេះភ្លើងគឺនៅខាងនោះទេ ។

ប៊ុនថន :	បាទ ចឹងផ្លូវមកមង្គលបុរី?

ផាន :	ផ្លូវផ្សារលើហ្នឹងណុ៎ អូនឯងមានស្គាល់ផ្លូវសាលាលើ?

ប៊ុនថន :	អត់ស្គាល់ផង ។

ផាន :	សាលារៀន សាលាសម្តេចឪ ។

ប៊ុនថន :	បាទៗ អូស្គាល់ហើយ ។

ផាន :	ចេញមកជិតៀរខាងត្បូង ។

ប៊ុនថន :	បាទៗ!

ផាន :	ដើរចុះទៅកើតចុះទៅផ្លូវមង្គលបុរី ។

ប៊ុនថន ៖ បាទៗ! ចឹងហ្នឹងតាហឹងខុសឆ្នាំមកប្រជុំកន្លែងហ្នឹង?

ផាន ៖ ហ្នឹងហើយកន្លែងសន្និបាតគេហ្នឹងហើយ ។

ប៊ុនថន ៖ កន្លែងៗហ្នឹងៗកន្លែងមេៗគេពីអី?

ផាន ៖ ទេ កន្លែងសន្និបាតនោះសម្រាប់ដល់ពេលគេហៅពួកមកជប់លៀង ដូចពួកខ្ញុំពួកអី ឲ្យគេជប់លៀងផងហើយគេហៅមកធ្វើការផង ។ កាលធ្វើការមិនរួច គេឲ្យដេកនោះហើយ ។

ប៊ុនថន ៖ ដល់ពេលប្រជុំអីគេច្រើននិយាយពីអីវិញ?

ផាន ៖ ហុឹម! មានតែការងារមានតែបង្កបង្កើនផលដែលយើងធ្វើស្រែហ្នឹងណា៎ ធ្វើស្រែនៅភ្នូរខ្លះពីរឿងស្រូវ ។

ប៊ុនថន ៖ ចឹងក្រៅពីគាត់ពីមានស្គាល់? តា ជៀល អីទេ? តា ហឹង?

ផាន ៖ ជៀល ខ្ញុំស្គាល់ ។

ប៊ុនថន ៖ ជៀល កូនតាញឹម?

ផាន ៖ ទេពុគេថា តាជៀលកូនតាញឹម ។

ប៊ុនថន ៖ បាទ!

ផាន ៖ តាជៀលខ្មោចដូចតាហឹងអីចឹងឯង តាជៀលនៅក្រោយគេណា៎ ចាប់ក្រោយអស់មានតាជៀលទេ ។

ប៊ុនថន ៖ តាជៀលហ្នឹងគាត់ធ្វើអីដែរ?

ផាន ៖ តាជៀលហ្នឹងដឹងថាគាត់ធ្វើធំដែល មិនដឹងថាអត់ហឹងទៅ ដូចគាត់ឡើងគណៈតំបន់នេះហ្នឹង ។ គាត់ឡើងម៉ាម្តងដូចតាហឹង ។ គាត់ឡើងម្តង ។

ប៊ុនថន ៖ តាហឹងដូចគេចាប់ឆ្នាំប៉ុន្មានពូ?

ផាន ៖ មិនដឹងឆ្នាំប៉ុន្មាន ពុតែ៧៨ៗ ដល់យើងមិនបានចំណាំៗ ។

ប៊ុនថន ៖ បាទ តាជៀលនឹងតាចយពីណាចាប់មុន? ដូចចាប់តាចយមុន? អឺចាប់តាហឹងមុន ឬចាប់តាចយពូ?

ផាន ៖ ចាប់តាហឹង ចាប់អ្នកធំ រួចចាប់ជើងដៃ ចាប់ទាហានយកតាមខ្សែ ។

ប៊ុនថន ៖ ចឹងណែតាហឹងចាប់ហើយបានតាជៀលមកជំនួសវិញ? មកប្រជុំមកអី?

ផាន ៖ តាហឹង ។

ប៊ុនថន ៖ តាជៀលម៉េចដែរដូចអត្តរិកអី? រាងអឺអញ្ចឹង?

ផាន ៖ ទេ ដល់គេធំទៅ មិនសូវដឹងដែរ ។ ប៉ុន្តែគាត់ជាទាហានអីមិនសូវដឹង ។

ប៊ុនថន ៖ ពេលឡើងនិយាយៗប្រជុំម៉ាដង?

ផាន ៖ តាជៀលខ្ញុំមិនសូវដឹងដូចខ្ញុំនៅក្រោយខ្ញុំមិនសូវនិយាយទេ អត់ហ៊ានមើលទេ តាជៀល ដូចថាគាត់ឡើងធំមែនដូច វល់វិកមិនមានអីចូល ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដូចថាមិនដែលបានប្រជុំអីទេ ។

ប៊ុនថន ៖ បាទ! ចុះក្រៅពីតាហ្នឹង? តើមានអ្នកផ្សេង អ្នកធំៗមកប្រជុំពីភ្នំពេញអីពូ?

ផាន ៖ ទេ! ដូចអត់ទេណោះ ។

ប៊ុនថន ៖ ពូស្គាល់តាញឹមទេពូ?

ផាន ៖ ទេ! មិនដែលស្គាល់ទេ តែឮតែឈ្មោះ ។

ប៊ុនថន ៖ រស់ញឹមពូ?

ផាន ៖ ថាឪៗតាជៀល ឮតែឈ្មោះ ។

ប៊ុនថន ៖ បាទ! គាត់ប្រធានភូមិភាគអីពូ?

ផាន ៖ បាទ! ឮគេថាអីចឹងហើយ ។

ប៊ុនថន ៖ ពូអីពូនៅកន្លែងអាត្រាក់ហ្នឹងប៉ុន្មានឆ្នាំពូ? នៅយូរៗទេ?

ផាន ៖ ខ្ញុំនៅតាំងពី៧៥រហូតដល់វៀតណាមចូល ។

ប៊ុនថន ៖ ពូភ្ជួរតែមួយមុខទេ? ពូថាដឹកថ្មអីមក ដឹកប្រជាជនអី?

ផាន ៖ ដឹកថ្មដង ដឹកទូ ដង ប្រជាជនខ្ញុំមិនបានដឹកទេ ខ្ញុំទៅក្រោយទេ កងជាមួយខ្ញុំគេដឹកមុន ។

ប៊ុនថន ៖ គេមុន?

ផាន ៖ ខ្ញុំមិនចេះបើកកាលហ្នឹង ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដល់ពេលគេហៅខ្ញុំទៅ ខ្ញុំអត់ទាន់ចេះ មានតែគេកងនៅមុនខ្ញុំ ។

ប៊ុនថន ៖ យើងទៅតាមគេទៅគេអ្នកបើក?

ផាន ៖ ខ្ញុំនៅកន្លែងឲ្យមកនៅក្នុងស្រុកនេះ ដល់ពេលគេរៀបបញ្ចូលរាស់ គេយកខ្ញុំទៅ ហើយគេឈប់ដឹកប្រជាជន ។

ប៊ុនថន ៖ អ្ហ៎! កាលណុងពូអត់ទាន់ទៅទេ? ពូអត់ទាន់ទៅស្វាយទេពូនៅភ្នំស្រុក?

ផាន ៖ ខ្ញុំគេហៅៗទៅស្វាយហ្នឹងហើយ ដល់ពេលគេហៅពីស្វាយមករស់នៅកន្លែងភ្នំស្រុក ផ្ទះនៅភ្នំស្រុកនេះអ្ហែង ហើយពួកវាហ្នឹង ។

ប៊ុនថន ៖ បាទ!

ផាន ៖ ពីមុនដំបូងដែលគេហៅទៅឲ្យផ្ទះតំបន់ស្វាយ ។

ប៊ុនថន ៖ បាទ! នៅបានប៉ុន្មានឆ្នាំពេលមក គេឲ្យពួមកនៅភ្នំស្រុកវិញ ។

ផាន ៖ ទៅនៅបាន៧ថ្ងៃហ្នឹង ។

ប៊ុនថន ៖ ៧ថ្ងៃ?

ផាន ៖ គេហៅខ្ញុំថាអ្នកចេះបើកអាត្រាក់ទេ គេហៅទៅកន្លែងដល់ដេកស្វាយមួយយប់ ព្រោះកន្លែងពួកវាមកនៅនេះអ្ហែង ។

ប៊ុនថន ៖ បាទ!

ផាន ៖ គេទៅនោះគ្រាន់តែដឹកប្រជាជន ។

ប៊ុនថន ៖ អ្ហ៎!

ផាន ៖ កន្លែងពួកគេមកនៅភ្នំស្រុក ដល់ពេលមកនៅភ្នំស្រុកគេបាននៅ ទួលសាលាក្រហម បណ្ដោយខំមកនេះមកនៅស្វាយ ។

ប៊ុនថន ៖ មកនៅស្វាយវិញ?

ផាន ៖ អ្ហ៎!

ប៊ុនថន ៖ ដឹកហ្នឹងដឹកអ្នកណាខ្លះពូ? ប្រជាជនមកពីភ្នំពេញ?

ផាន ៖ ទេ ថាៗអ្នកថ្មីៗ ។

ប៊ុនថន ៖ ដឹកមកដាក់ណាខ្លះពូអី?

ផាន ៖ នៅស្វាយ ។

ប៊ុនថន ៖ ដឹកមកដាក់ណាខ្លះពូពួកនោះ?

ផាន ៖ ដឹកៗណាៗទេ ប៉ុនដឹកមកដល់ភ្នំស្រុក ដែលប្រជាជនមកកាលណោះរទេះហ្នឹងណា រទេះដឹកមកភ្នំស្រុកតមកទៀត ។

ប៊ុនថន ៖ បាទ! ដឹកតាមអាត្រាក់?

ផាន ៖ ដឹកមកដល់ណោះទេ ហើយឡានអាត្រាក់មិនមកដល់នេះទេ

ប៊ុនថន ៖ អាត្រាក់មកដល់ភ្នំស្រុកដឹកហ្នឹង ប៉ុនប្រជាជនហ្នឹងយកមកដាក់?

ផាន ៖ តាមភូមិ ។

ប៊ុនថន ៖ ទៅដឹករទេះយកតមកទៀត?

ផាន ៖ គេណួរទេះ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដល់ពេលឈប់ភ្ជួរស្រែតើ ទើបពួកខ្ញុំជីកថ្ម ពេលគេចាប់ធ្វើល្អាងត្រពាំងថ្មនេះធ្វើស្ពានហើយមកនេះហើយគេកេណ្ឌអាត្រាក់មកជីកថ្ម រួចភ្ជួរ ។

ប៊ុនថន ៖ កាលហ្នឹងឆ្នាំប៉ុន្មាន? ចិតប៉ុន្មាន.?

ផាន ៖ ដូច៧៦,៧៧អី ខាងលើកទំនប់ ។

ប៊ុនថន ៖ ពូៗ ស្មានខ្លួនឯងហ្នឹងប្រហែលជាពេលប៉ុន្មានពេលប្តូរមកខាងជីកថ្ម?

ផាន ៖ ដូច៧៦,៧៧ហ្នឹងអែង ។

ប៊ុនថន ៖ ចុង៧៦ឬក៏កណ្តាល?

ផាន ៖ ប្រហែលជាចុង៧៦ហ្នឹង ។ ព្រោះគេលើក ខ្ញុំចាប់ផ្តើមជីកថ្មគេចល័ត គេលើកមុន ។

ប៊ុនថន ៖ លើមុនហើយ? កាលហ្នឹងមានដូចថាមិនទាន់លើកអីធំដុំអី? ដែលថាឃើញវាល?

ផាន ៖ បាទ ។ កាលហ្នឹងលើកមុន ហើយគេចាប់ឲ្យពួកខ្ញុំជីកថ្មធ្វើស្ពាន ខ្ញុំមិនដឹងថាស្ពានទេអីគេថាឲ្យជីកៗ ចេះតែជីកប៉ុនណោះអែង ។

ប៊ុនថន ៖ បាទ!

ផាន ៖ ស្រេចគេប្រើ ។

ប៊ុនថន ៖ ជីកច្រើនទេពូជីកច្រើនទេ?

ផាន ៖ ជីករាល់ថ្ងៃ ។

ប៊ុនថន ៖ ប៉ុន្មានអាត្រាក់ពូ?

ផាន ៖ អាត្រាក់នៅៗ មិនដឹងថាប៉ុន្មានទេ អាត្រាក់ប្រហែលជា៧ទៅ៨ ។

ប៊ុនថន ៖ បាទ៨?

ផាន ៖ ក្នុងម៉ាកងខ្ញុំ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ភ្នំលាបមក ។

ប៊ុនថន ៖ ភ្នំលាប?

ផាន ៖ ក្រោយមកទៀត ទើបជីកភ្នំត្រយោង ។

ប៊ុនថន ៖ ភ្នំតាយោងនៅណាវិញពូ?

ផាន ៖ ជិតគ្នាហ្នឹងណា៎ ភ្នំលាបភ្នំត្រយោង ។

ប៊ុនថន ៖ បាទ!

ផាន ៖ ប៉ុនខ្ញុំចាប់ផ្ដើមដឹកមុនដំបូងដឹកភ្នំលាប ក្រោយមកទើបចល័តដឹកភ្នំត្រយោងទៀត ។

ប៊ុនថន ៖ អាត្រាក់ហ្នឹងយើងរម៉កពីក្រោយ យើងដាក់អូសដែរពូអី?

ផាន ៖ បាទ ។ រម៉ក ។

ប៊ុនថន ៖ អូសហ្នឹងពូអី? អូម៉ាដងបានប៉ុន្មានម៉ែត្រគីប?

ផាន ៖ មិនដឹងថាប៉ុន្មានម៉ែត្រគីប ហើយដាក់រម៉កចុះ គេដល់មានចល័តគេលើកដាក់អូសឲ្យយើងអ្នកបើកគ្រាន់តែដឹកតែប៉ុនណោះហ្នឹងហើយ ។ កាលាដាក់ពេញយើងដាក់មក មកនេះមានចល័តទៀត ។

ប៊ុនថន ៖ អ្ហូ! ណោះមានចល័តទៀត?

ផាន ៖ បាទ ។ ដូចថាចល័តគេចាត់ចែងដប់នាក់ចឹងអី ។

ប៊ុនថន ៖ បាទ!

ផាន ៖ ក្នុងម៉ាក្រុមសម្រាប់ដាក់ថ្មម៉ាអាត្រាក់ ។

ប៊ុនថន ៖ ដឹកថ្មៗប៉ុនៗណាពូ?

ផាន ៖ អាថ្មធំៗប៉ុនណោះប៉ុនណោះ អាថ្មគេវៃបំបែក ដូចថ្មអីចឹង ។

ប៊ុនថន ៖ បាទ ។ មិនមែនថ្មតូចៗល្អិតៗអីទេ?

ផាន ៖ អាតូចក៏មាន ចល័តវៃម៉ែត្រគីប ។

ប៊ុនថន ៖ ចល័ត?

ផាន ៖ ចល័តនៅភ្នំហើយម៉ែត្រគីប ។ មិនមែនទិញទេ គេឲ្យវៃម៉ែត្រគីវាស់ស្អាត ។

ប៊ុនថន ៖ វាស់ម៉ែត្រគីប?

ផាន ៖ ហើយតើម្នាក់វាស់បានប៉ុន្មានម៉ែត្រគីប យើងម្នាក់គេឲ្យបានមួយម៉ែត្រគូប ទេប៉ុនអាត្រូវគេមាន អាល្អិតក៏មាន ប៉ុនគេត្រូវការល្អិតមាន ។

ប៊ុនថន ៖ បាទ!

ផាន ៖ បើត្រូវការអាធំយើងដឹកអាធំ ។

ប៊ុនថន ៖ បាទ! មានទាំងអស់?

ផាន ៖ អាប៉ុមេៗដើងហ្នឹងណាំ អាគេវៃប៉ុនមេដើងហ្នឹងណាំ ។

ប៊ុនថន ៖ ចុះពូដូចអាលើកអាធំៗនេះមាន? ដូចលើកដៃតែហ្មង?

ផាន ៖ អាធំៗប៉ុនណោះលើកដៃបោះ យើងលើកល្មមបោះខ្នងអាត្រាក់ លើកចេញ ។

ប៊ុនថន ៖ ហើយមានអាថ្មធំៗ?

ផាន ៖ អាធំៗមានវែវបំបែកៗ

ប៊ុនថន ៖ វែវបំបែកទៀត?

ផាន ៖ ដែលគាស់លើភ្នំធំណា៎ បណ្តោយប៉ុនណោះទទឹងធំប៉ុនណោះៗ

ប៊ុនថន ៖ បាទ!

ផាន ៖ គាស់មកភ្នំមិនមានអាញញួរស្រាប់ វែ..បំបែកៗអាប៉ុនៗណោះ ប៉ុនៗណោះមកបោះលើទម្លាក់អស់រលីងពីលើភ្នំមក?

ប៊ុនថន ៖ អត់មានអូ៎ម៉ាស៊ីនអី?

ផាន ៖ ទេៗ

ប៊ុនថន ៖ អត់មានម៉ាស៊ីនអីវែវបំបែកទេ?

ផាន ៖ មុនដំបូងអត់មានម៉ាស៊ីនទេ និយាយពីម៉ាស៊ីអត់មានដូចសព្វថ្ងៃហ្នឹងទេ ធ្វើម៉ាម្តងម្នាក់មានអាពួកដោកដឹកថ្មដាក់ហ្នឹងណា៎ៗ

ប៊ុនថន ៖ បាទ!

ផាន ៖ គេហៅអាបៀលៗ ខ្ញុំមិនព្វទេ គេហៅអាបៀល ដូចទៅអានោះវាខូតអស់ គេអត់ពេលផ្លាស់ទាំងនោះខូតអស់ ហើយសុទ្ធតែមនុស្សៗ

ប៊ុនថន ៖ មនុស្ស? ច្រើននាក់ទេពូ?

ផាន ៖ លើកបួនដប់នាក់ទៅ បួនប្រាំដប់នាក់ទៅ ដូចថាអាគ្រាក់មួយដឹកម្នាក់លើកបោះដាក់ៗ

ប៊ុនថន ៖ បាទ!

ផាន ៖ ពេញមកហើយបើកមក ហើយមកណោះក៏មានគេជួយទម្លាក់អីទៅៗ

ប៊ុនថន ៖ ដឹកទៅមកដល់អាត្រពាំងថ្មនេះហ្នងពូ?

ផាន ៖ ដល់ស្ពានទីមួយនេះៗ

ប៊ុនថន ៖ ស្ពានទីមួយ?

ផាន ៖ ស្ពានទីមួយស្ពានទីពីរៗ

ប៊ុនថន ៖ មានប៉ុន្មានស្ពានលោកពូកាលហ្នឹង?

ផាន ៖ មានពីរស្ពានៗ បីស្ពានៗ

ប៊ុនថន ៖ បី?

ផាន ៖ ហើយអានេះខ្ញុំមិនសូវបានដឹកនេះទេ មកដល់ប៉ុន្មានថ្ងៃខ្ញុំទៅវិញៗ គេដឹកភ្នំគូលែន ហើយអាណុងមានតែដឹកយូររាល់ឆ្នាំៗ ខ្ញុំនៅភ្នំតាយោងៗ

ប៊ុនថន ៖ ភ្នំតាយោង? អីពូជីកមកហ្នឹងដូចថាមានអ្នកធ្វើការច្រើនទេ.?

ផាន ៖ ច្រើនដែលចល័ត ។

ប៊ុនថន ៖ គេចល័ត?

ផាន ៖ គគ្រឹកគគ្រេងពេញ ។

ប៊ុនថន ៖ ហើយប៉ុន្មាននាក់ទៅពូ?

ផាន ៖ រាប់រយរាប់ពាន់ចល័ត ។

ប៊ុនថន ៖ ឃើញហ្នឹងសុទ្ធតែមនុស្សហ្នឹងអីពូ?

ផាន ៖ សុទ្ធតែមនុស្សអូរឡូសញោះ ។

ប៊ុនថន ៖ បាទ!

ផាន ៖ អ្ហ៎! មិនមែនមនុស្សច្រើនលើកតែទំនប់បានទេ ទំនប់ប៉ុនណ៎ាណី ។

ប៊ុនថន ៖ ពេលដូចថាបើកមកដល់ហើយអឺយើងបានឈប់សម្រាកអីគេ?

ផាន ៖ ណោះហើយយើងឈប់សម្រាកទៅ ។

ប៊ុនថន ៖ ហើយយើងទៅ?

ផាន ៖ បើអ្នកណាបោះឆ្នាក់ទំលាក់ថ្ម ចាំទម្លាក់ទៅណ៎ា ហើយអ្នករែកដី ក៏រែកដីផ្សេង វាមានការងាររវាផ្សេងៗពីគ្នា ។

ប៊ុនថន ៖ បាទ!

ផាន ៖ ប៉ុនយ៉ាប់គ្នាវាមិនស៊ីឆ្អែត ។

ប៊ុនថន ៖ ហើយអ្នកណានៅចាំទទួលនៅនេះ? ដូចថាមានដែលគេចាំកត់ថាៗបានប៉ុន្មានៗ?

ផាន ៖ អត់ដែលមានកត់ទេ ។

ប៊ុនថន ៖ យកមកចាក់ៗចឹងហ្នង ។

ផាន ៖ ចាក់ៗ អត់មានអ្នកកត់ទេ ដាក់ដែលអត់អ្នកមើលធ្វើទេ ទំលាក់ៗដូចថា មានអ្នកគេស្គាល់ ។ ពួកគេថាទំលាក់ណ៎ា ក៏ទំលាក់តាណោះអែង ។

ប៊ុនថន ៖ បាទ!

ផាន ៖ អត់មានមើលមកកត់ដូចថាយើងសព្វថ្ងៃនេះទេ ទំលាក់តាណោះហើយ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដូចថាថ្មមកទំលាក់តាណោះទៀត ។

ប៊ុនថន ៖ ចុះស៊ីម៉ីងហើយដែកអី?

ផាន ៖ អានោះគេដឹកឡានផ្សេង ។

ប៊ុនថន ៖ មិនមែនខាងពួដឹកទេ?

ផាន ៖ ទេ! នៅខាងពាណិជ្ជៗ ។

ប៊ុនថន ៖ ពាណិជ្ជកម្មផ្សេង?

ផាន ៖ បាទ ។ ពាណិជ្ជកម្មគេផ្សេងទៀត ។ ពួកខ្ញុំដឹកតែថ្ម មិនមានឡានគេអីហ្នឹងអែង, ។

ប៊ុនថន ៖ ម៉ាថ្ងៃប៉ុន្មានជើងពួដឹក?

ផាន ៖ បានប៉ុន្មានទេ បានពីរជើងហ្នឹងណា៎ ។

ប៊ុនថន ៖ ម៉ាថ្ងៃពីរជើង?

ផាន ៖ បាទ ។

ប៊ុនថន ៖ ព្រឹកល្ងាច?

ផាន ៖ ព្រឹកល្ងាច ។

ប៊ុនថន ៖ ហើយពីណាដឹកនាំដឹកហ្នឹងពួ?

ផាន ៖ ទេនោះអាស្រ័យដូចថាប្រធានគេណោះ គេត្រូវការ គេប្រាប់ប្រធានខ្ញុំឯណោះ ។

ប៊ុនថន ៖ បាទ!

ផាន ៖ គេប្រើ ។

ប៊ុនថន ៖ ប្រធានពួអឹតាចយដដែល?

ផាន ៖ ទេ ប្រធានក្តាប់តដូចគាត់មកប្រធានកងអនុ ប្រធានកងវិញ ។

ប៊ុនថន ៖ ពីណាគេ?

ផាន ៖ គ្រាន់តែខ្ញុំដឹកមុនដំបូងឈ្មោះយឿន អនុប្រធានកង គានួយ ។

ប៊ុនថន ៖ គានួយទៀត?

ផាន ៖ ដូចថាគាត់នៅក្តាប់ពួកខ្ញុំ ។

ប៊ុនថន ៖ គាត់ប្រធានកងតូច?

ផាន ៖ កងតូច ។

ប៊ុនថន ៖ ៣០ នាក់ពួ?

ផាន ៖ បាទ! ដូចនិយាយថាប្រធានទីបី ។

ប៊ុនថន ៖ ប្រធានទីបី?

ផាន ៖ ប៉ុនតែ ប្រធានទីបីនោះ ពេលធ្វើការអីគាត់ឲ្យថាអីទេ គាត់ចេះអក្សរ បើប្រធានកង
ធំជាងគាត់អត់ចេះអក្សរ ។ យើងថាដូចទិទៀតចុះហើយ ។

ប៊ុនថន ៖ អ្ហ៎!

ផាន ៖ យើងឌឹគាត់ ដូចប្រធានធំអត់ចេះអក្សរ គិចនិយាយអីចាញ់គាត់ ។

ប៊ុនថន ៖ អ្ហ៎! និយាយចាញអនុប្រធាន?

ផាន ៖ ហ្នឹងហើយ ។

ប៊ុនថន ៖ ចឹងអត់ហ៊ានទិទៀតគាត់ទេ?

ផាន ៖ ទេ អនុប្រធានទិទៀន ។

ប៊ុនថន ៖ អ្ហ៎!

ផាន ៖ តែគាត់មិនចេះអក្សរ ។

ប៊ុនថន ៖ ពីណាពូថាឈ្មោះអីគេវិញ?

ផាន ៖ តាយឿន ។

ប៊ុនថន ៖ ឈ្មោះយឿន? ហើយតាប្រធានអត់ចេះហ្នឹងឈ្មោះអី?

ផាន ៖ តានួយ ។

ប៊ុនថន ៖ គាត់នៅរស់ទេពូ?

ផាន ៖ ទេ! បងយឿននៅរស់តើ ។

ប៊ុនថន ៖ បងយឿន?

ផាន ៖ បើតានួយនោះគេចាប់ហើយ ។

ប៊ុនថន ៖ គាត់នៅណាតាយឿននោះ?

ផាន ៖ តាយឿននោះដូចថាគាត់នៅរស់ ។ អាកាលម៉ាដងគាត់នៅស្វាយ ខ្ញុំនៅស្វាយ ។

ប៊ុនថន ៖ អ្ហ៎?

ផាន ៖ ហើយសព្វថ្ងៃមិនដឹងម៉េចទេ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ឃើញនៅស្វាយដែល ហើយមានបងប្អូនគេមានកាលណោះ គេហៅតានួយៗ ។

ប៊ុនថន ៖ បាទ! ពូមកដឹកនេះបានរយៈពេលប៉ុន្មានពូ?

ផាន ៖ ដឹកនាំមក?

ប៊ុនថន ៖ បានប៉ុន្មាន?

ផាន ៖ ដឹកយូរណោ៎ ដឹករាប់ឆ្នាំដឹកទាល់តែវៀតណាមចូល ។

ប៊ុនថន ៖ ដឹកមកត្រពាំងថ្មហ្នឹងពូ?

ផាន ៖ អ្ហ៎! ទើបធ្វើល្អានហ្នឹងណា៎ ធ្វើល្អានរួចហើយលី ។ **(ត)**

ប៊ុនថន ៖ តា មោង ហើយតា ម៉ៅ លោកពូ?

ផាន ៖ បាទ ។

ប៊ុនថន ៖ ហើយគាត់ពីនាក់ហ្នឹងដូចថាអ្នកមើលកម្មករមើលអីអ្នកធ្វើហ្នឹងពូ?

ផាន ៖ បាទ មេផាន ។

ប៊ុនថន ៖ អ្នកខាងសំណង់ហ្នឹងច្រើនទេពូ?

ផាន ៖ ច្រើនហ្នឹងណា កូនផាន ។

ប៊ុនថន ៖ ប៉ុន្មាននាក់ពូ?

ផាន ៖ ប៉ុន្មានៗ ខ្ញុំមិនដឹងប៉ុន្មាននាក់ផង ។

ប៊ុនថន ៖ ច្រើនដែរ?

ផាន ៖ បាទ ។

ប៊ុនថន ៖ ធំទេស្ពានហ្នឹង?

ផាន ៖ ធំអូនឯងមិនដែលឃើញទេ!

ប៊ុនថន ៖ អត់ដែលទេ!

ផាន ៖ គេធ្វើថ្មីធ្វើរន្ធតូចៗ ពីដើមមិញគេធ្វើទ្វារធំៗ ។

ប៊ុនថន ៖ បណ្ដោយប៉ុន្មានពូ?

ផាន ៖ ស្ពាន់នោះមិនដឹងបណ្ដោយប៉ុន្មានម៉ែត្រ ។ ស្ពាននោះបណ្ដោយពីនេះទៅផ្ទុះមិនដឹង ។ អា បណ្ដោយពីនេះទៅនោះ មានតែវែងនោះ ។

ប៊ុនថន ៖ ប្រហែលជាប៉ុន្មានម៉ែត្រ ២០ម៉ែត្រ ១០ម៉ែត្រទេ?

ផាន ៖ ១០ម៉ែត្រផាន ។

ប៊ុនថន ៖ ស្ពានបិទបើកទឹកហ្នឹងពូ?

ផាន ៖ ហ្នឹងហើយ ។

ប៊ុនថន ៖ អ្ហ៎!

ផាន ៖ ពីដើមមិញធ្វើទ្វារធំៗ ធ្វើអាសន្ទឹកទ្វាររាំងឈើ ដល់សព្វថ្ងៃធ្វើមុខតូចៗដល់ធ្វើថ្មីទៀត ។ បាទ! ថ្មីមុខវាធំ ។

ប៊ុនថន ៖ បាទ!

ផាន ៖ គេធ្វើឡើងស្អាត សម័យនោះធ្វើមិនទាន់ស្អាតទេ ។ វាធ្វើមិនទាន់រូបណា រួចស្រួលបួលផង វៀតណាមចូលមក ។ វាវាយជាងចោលអស់ផង ក្រោយមកជាងនោះវាយចោលអស់ទៀត ។

ប៊ុនថន ៖ ម៉េចបានយកទៅវាយពូ?

ផាន ៖ ទេដឹងសម័យនោះ ដឹងម៉េចចោះហើយ ឧទាហរណ៍ថា វាចាប់ប្រធានអញ្ចេះ ឧបមារថា ប្រធានក្តាប់ពីលើជាងទៀតណា ។ ចាប់គណៈតំបន់មួយសារចឹងទៅ គេចាប់ទាំងជាងទាំងអីថាសុទ្ធតែខ្មែរ ។

ប៊ុនថន ៖ បាទៗ!

ផាន ៖ ដូចថាដឹកស្មៅដឹកទាំងឫស ចោះអញ្ចឹងបានថាយកទាំងអស់ ។

ប៊ុនថន ៖ ពូដឹងតាមពីណាពូយកជាងទៅសម្លាប់ហ្នឹង?

ផាន ៖ ទេ វាមិនដឹង ដូចថាខ្ញុំនៅបើកបរ ។ ខ្ញុំគ្រាន់តែថា គេប្រាប់ថា អ្ហ៎! គេយកទៅវាយចោលអស់ហើយ មិនដឹងថាឈ្មោះណាមិនដឹង ។

ប៊ុនថន ៖ បាត់ខ្លួនគាត់ឬមួយបាត?

ផាន ៖ ដឹងតែបាត់ខ្លួនគាត់ ។

ប៊ុនថន ៖ បាត់គាត់?

ផាន ៖ បាត់គាត់ តែបាត់ហើយសម័យនោះគេថាមានទៅណា មានតែងាប់ ។ ប៉ុនងាប់ អារឿងគាត់ងាប់មិនងាប់ មិនដឹងទេ ប៉ុន្តែបាត់ ។ មុនដំបូងគេបាត់តា មោង ប្រធាន ។

ប៊ុនថន ៖ តាមោង!

ផាន ៖ បាទ នៅតែតា ម៉ៅ ។

ប៊ុនថន ៖ តាម៉ៅ!

ផាន ៖ ប៉ុន្តែរង តាម៉ៅ ហ្នឹងគាត់ខ្មៅ...ក្រោយមកនេះបានចាប់តា ម៉ៅ ទៅទៀត បាត់តា ម៉ៅ ទៅទៀត ។

ប៊ុនថន ៖ មេជាងហ្នឹងមានតែខ្មែរទេ?

ផាន ៖ សុទ្ធតែខ្មែរ ។

ប៊ុនថន ៖ ហឺអត់ពួកនេះទេ?

ផាន ៖ បរទេសទេ ។

ប៊ុនថន :	អត់មានចិន វៀតណាមទេ?

ផាន :	អត់មានទេ ។ សុទ្ធតែជាង និយាយទៅជាងនៅពីសង្គម ពួកជាងជំនាន់នោះមិនមែនធ្វើផ្ទះថ្មអីទេជំនាន់នោះ ។

ប៊ុនថន :	បណ្តោយមិញថាជាង១០ម៉ែត្រ ចោះទទឹងធំដេះ?

ផាន :	ទទឹងធំដែរ?

ប៊ុនថន :	ប្រហែលប៉ុន្មាន២០ម៉ែត្រ ១០ម៉ែត្រ ក៏ប៉ុន្មាន?

ផាន :	ទេមិន១០ម៉ែត្រផងក៏មិនដឹង ។

អ្នកជិតខាង:	ទទឹងវាធំដែរ អ្ហឺ! ១០ម៉ែត្រ យូរទៅក៏ឃើញ...។

ផាន :	ទៅសព្វថ្ងៃមើលមិនដឹងទេ គេធ្វើតែម៉ាចុះឡានប៉ុណ្ណោះឯង ។ ពីដើមមិញគេធ្វើឡើងធំសព្វថ្ងៃទៅមើលល្អូរល្ហេវ ភូមិ ធ្វើថ្មីទៀត ។

ប៊ុនថន :	បាទ!

អ្នកជិតខាង:	កាលនោះដែលមានកម្លាំង...។

ផាន :	ពីដើមមិញធ្វើធំហ្នឹងឯង សព្វថ្ងៃគេរៀបចំឡើងស្អាត គេធ្វើម៉ាចតឡាន១ ។ អានោះមើលចេះ បើមើលពីស្ពានទីមួយបៀតអាបត់កែង ឈរមើលស្ពានទីមួយកាលដែលទឹកច្រើនសឹងតែជាប់មេឃទៅ ។

ប៊ុនថន :	បាទ!

ផាន :	ធំណាស់គេថាធំជាងអាងកំពីងពួយ ។ ក្មួយមានដែលឃើញអាងកំពីងពួយទេ ខ្ញុំឮតែគេថា!

ប៊ុនថន :	កំពីងខ្ញុំដែលទៅដល់ដែរ ។

ផាន :	ឮតែគេថាអាងកំពីងពួយៗ ខ្ញុំក៏មិនដែលឃើញ ប៉ុនគេថាអាងនេះធំជាងអាងកំពីងពួយទៀត ។

ប៊ុនថន :	អានេះប្រហែលជាបណ្តោយប៉ុន្មានពូ?

ផាន :	ប៉ុណ្តោយដឹងប៉ុន្មានគីឡូទេ ។ បណ្តោយបើរាប់ទៅវាវែង មកដល់នេះៗដូចថា ប្រជាជនធ្វើស្រែ ចោលដីស្រែណាដែលធ្វើមិនកើត ។ បើគិតទៅប៉ុន្មានគីឡូទេ ៨-១០គីឡូដឹងបណ្តោយ ។

ប៊ុនថន :	អាងហ្នឹងនៅក្នុងភូមិឃុំអីដែរអាងហ្នុងសព្វថ្ងៃ?

ផាន :	អាងនោះវានៅភូមិប៉ោយចារ ។

ប៊ុនថន :	ភូមិប៉ោយចារ?

ផាន ៖ វាជិតជាងភូមិនេះ ជិជាងប្រភពទន្លេ ។

ប៊ុនថន ៖ ពីកន្លែងហ្នឹងទៅប៉ុន្មានពូ?

ផាន ៖ ពីនេះទៅ បើទៅត្រង់ទៅអត់ឆ្ងាយទេ ប្រហែលបីគីឡូជាង ។ បើទៅបញ្ឆិតទៅរកឯណោះ បីបួនគីឡូ ប្រាំគីឡូ ។ បើទៅនោះទៀត ស្ពានទីមួយទៀតកាន់តែឆ្ងាយ ។ បើថាយើងទៅត្រង់ចេះបីបួនគីឡូនេះឯង ថាបួនចោះ ប្រាំចោះ ។ វាមិនដល់អាងធំទេ គ្រាន់តែថាចុងអាងប៉ុណ្ណោះ បានដល់អាងធំ ។

ប៊ុនថន ៖ ចោះលើ តាមោង និងតា ម៉ៅ ហ្នឹងពីណាទៀតពូ មេគាត់ធំ?

ផាន ៖ ទេ អត់មានទេ ។

ប៊ុនថន ៖ អត់មានទេ?

ផាន ៖ មានតែគាត់ប្រធានធំជាងគេ ប្រធានជាង ប្រធានជាងស្ពាន ។

ប៊ុនថន ៖ ចោះខាងមើលលើគាត់អត់មានទេ ពូអត់ស្គាល់?

ផាន ៖ លើគាត់អត់មានទេ មានតែថ្នាក់តំបន់ប៉ុណ្ណឹងឯង ។

ប៊ុនថន ៖ ពីណាអ្នកមើល?

ផាន ៖ ពីដើមមិញ ថ្នាក់តំបន់គេយកទៅ ដល់ក្រោយមកក៏បាត់គាត់ទៅ បាត់បន្តបន្ទាប់គ្នា ។

ប៊ុនថន ៖ តាហឹង១ អ្ហឺ! អ្នកគ្រប់នៅហ្នឹងតែម្តងពូ កន្លែងទំនប់?

ផាន ៖ អ្ហ៊ូ! គាត់ដូចគ្រប់គ្រងម៉ាតំបន់ បើកន្លែងគ្រប់គ្រងចល័តនៅនេះខ្ញុំអត់ដឹងទេ ខ្ញុំមិនសូវដឹង ។

ប៊ុនថន ៖ ចោះ តាវ៉ាល់ អី?

ផាន ៖ តាវ៉ាល់ ក៏គាត់គ្រប់គ្រងចល័តនោះដែរ ប៉ុនមិនដឹងគ្រប់គ្រងម៉េច ស្គាល់ដែរហ្នឹងខ្ញុំ ។

ប៊ុនថន ៖ ជួប ដែលជួបទេ?

ផាន ៖ ជួប ប៉ុន្តែជួប ប៉ុន្តែមិនដែលបាននិយាយចូលគ្នា គ្រាន់តែថា អ្ហ៊ូ! តានេះ តាវ៉ាល់ ។

ប៊ុនថន ៖ ប៉ុនគាត់ដែលមកមើលកន្លែងពូជីកថ្មមកដាក់ទេ?

ផាន ៖ ទេអត់ដែលមកទេ កន្លែងនៅផ្សេងអង្គភាពរបស់ខ្ញុំ ។

ប៊ុនថន ៖ ប៉ុនពេលជីកថ្មទៅដល់ហ្នុង?

ផាន ៖ ខាងចល័តខាងប្រជាជន នោះវាផ្នែកផ្សេង ។

ប៊ុនថន ៖ តាវ៉ាល់ ចោះ តាមោងពូមានមានស្គាល់ទេ?

ផាន ៖ តាមោង!

ប៊ុនថន ៖ បាទ! តាម៉ោង?

ផាន ៖ អ្ហ៍! តាមោង គាត់មានអ្នកក្តាប់ចល័តទេ ។

ប៊ុនថន ៖ គាត់ខាងអីវិញ?

ផាន ៖ គាត់ខាងយោធា ។

ប៊ុនថន ៖ ខាងយោធា?

ផាន ៖ បាទ ប៊ុនគាត់ផងដឹង ប៊ុនដឹងគាត់ក្តាប់ខាងណា ។ ប៊ុន តាមោង សួវនេះទេ ប៊ុនខាងកាល ពីនៅកាលស្រុកមិនទាន់សន្តិភាពអានេះឈ្មោះគាត់ហើយខ្ញុំស្គាល់គាត់ដែរ គ្រាន់តែស្គាល់ៗ ឃើញមុខគាត់តិចតួចដែរ ក៏បាននិយាយជាមួយគេ គេធំៗ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដឹងឃើញតែរូបគាត់ ។

ប៊ុនថន ៖ ចោះថាមាន តាសន តាអីទៀតកាលហ្នុង?

ផាន ៖ តាសន អត់ស្គាល់ ។

ប៊ុនថន ៖ ហ្អូពូអត់សូវស្គាល់ខាងទំនប់នេះទេ?

ផាន ៖ អត់សូវស្គាល់ទេ ប្រធានៗគេ ។

ប៊ុនថន ៖ បាទ!

ផាន ៖ បើខ្ញុំដឹកជញ្ជូនថ្មឲ្យគេទៅ ។ ណ៎ា! បើសិនណាយើងនៅចល័តនៅទំនប់នោះបានស្គាល់ ប្រធានៗ ប្រធានកងអីនោះ ។

ប៊ុនថន ៖ ចោះពូដឹកហើយ ទៅសម្រាកអីនៅណាពូ?

ផាន ៖ នៅភ្នំត្រយ៉ូង ។

ប៊ុនថន ៖ ទៅសម្រាកនៅភ្នំត្រយ៉ូង?

ផាន ៖ បាទ ។

ប៊ុនថន ៖ ចឹងភ្នំត្រយ៉ូង និងភ្នំលាបជាប់គ្នាពូ?

ផាន ៖ បៀតគ្នា ។ មិនជាប់ទេ ប៉ុនជិតគ្នា ។

ប៊ុនថន ៖ បាទ! ចឹងម៉ាក្រុមរបស់ពូហ្នឹងប៉ុន្មាននាក់នៅសម្រាក់នៅហ្នឹងពូ?

ផាន ៖ ប្រហែល៣០នាក់ ។

ប៊ុនថន ៖ ៣០នាក់ ។ ចោះមានផ្លាស់ប្តូរគ្នាដេះពូ?

ផាន ៖ ទេ ។

ប៊ុនថន ៖ ដឹករហូត?

ផាន ៖ គេក៏ដឹកយើងក៏ដឹក ។ ដូចថាអាត្រាក់មួយក៏បើកពីនាក់ចេះទៅ ក៏ដូរគ្នាម្នាក់ម្ដង ដូចថាខ្ញុំមកមួយដើងចឹងទៅ លើកក្រោយឲ្យគេមក ។

ប៊ុនថន ៖ ច្រើនទេពូបើថាគិតជាថ្ងូ ការគិត?

ផាន ៖ ច្រើន ហើយកចល័តទៅវាយចោលរាល់តែថ្ងៃ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ចល័តទៅវាយថ្មរាប់រយ ។

ប៊ុនថន ៖ បាទ! រាប់រយ?

ផាន ៖ បាទ មានអាវាយថ្មតូច មានអាវាយថ្មធំ ។ ទោះបីតែខ្ញុំសម្រាកមិនបានដឹក ចល័តត្រូវតែវាយ វាយទុក ។

ប៊ុនថន ៖ អ្ហូ! ចឹងពូមានពេលសម្រាកដែរ?

ផាន ៖ មានដែរតើ ។

ប៊ុនថន ៖ សម្រាកម្ដងប៉ុន្មានថ្ងៃ?

ផាន ៖ គេឈប់ៗ ត្រូវការថ្មអីចឹង សម្រាកទៅពីរបីថ្ងៃទៅ ។ បើថាគេ អ្ហូ! ត្រូវការថ្មទៀតហើយក៏ទៅទៀតទៅ ។

ប៊ុនថន ៖ សម្រាក ពេលសម្រាកហ្នឹងយើងធ្វើអី យើងសម្រាកម្ដង ក៏សម្រាកនៅកន្លែងយើងទៅ?

ផាន ៖ មានធ្វើអីទេ បាទ សម្រាកមានធ្វើអី ។

ប៊ុនថន ៖ ប៉ុនដឹកអាហ្នឹងអត់សូវហត់ទេពូដឹកថ្មនេះ ប៉ុនយើងបើក?

ផាន ៖ វាគ្រាន់ជាងចល័តលើកដី ។

ប៊ុនថន ៖ បាទ!

ផាន ៖ ធូរជាង ហើយហូបបានឆ្អែតជាងផង ។

ប៊ុនថន ៖ ពីភ្នំនិយាយពីភ្នំត្រយ៉ូងមកត្រពាំងប៉ុន្មានគីឡូកាលហ្នុងពូ?

ផាន ៖ ដឹងប៉ុន្មាន សម័យនោះដែលគិតគីឡូគិតអី ។

ប៊ុនថន ៖ បើតាមពូស្មានសព្វថ្ងៃពូ?

ផាន ៖ ឆ្ងាយណាស់ ណា៎!

ប៊ុនថន ៖ សព្វថ្ងៃ?

ផាន ៖ ឆ្ងាយជាងពីដប់មកភូមិនេះទៀត វានៅតែឯកើតអីនោះ ។

ប៊ុនថន ៖ ជាង២០គីឡូអីទេពូតាមគិត?

ផាន ៖ ជាង ប្រហែលចូល៣០អីដឹង ៣០គីឡូ ។

ប៊ុនថន ៖ ប្រហែលជា៣០គីឡូពូណេះ?

ផាន ៖ បើមិន៣០ក៏២៥គីឡូអីនេះ ។ យើងពីនេះទៅដប់ប៉ុន្មាន១៩គីឡូ!

អ្នកជិតខាង៖ ១៩ ។

ផាន ៖ អ្ហ៊ូ! រយៈ៣០ហើយមើលទៅ ។ សាច់ពីភ្នំលាបមកដល់ផ្លូវព្រៃមាន់ទៀត សាច់ចាប់ពីព្រៃមាន់មកណេះទៀត ។

ប៊ុនថន ៖ បាទ!

ផាន ៖ ពួកខ្ញុំដែលនៅដូចគេហៅថា អន្តភាព បើកអាគ្រាក់ៗ ពួកអន្តភាព គេគិតថា អន្តភាពៗប៉ះត្រង់ណា បើនៅភ្នំត្រយ៉ូង ដល់នេះបើករបបចល័តដែរហូប ។ ម្តងនោះបើករបបចល័តមិនហូបឆ្អែតទេ ។ ដល់ពេលយកបាយ យកអង្ករនោះមកបបរក៏បានម្នាក់ពីរចានកំប៉ុត មានអីហូបឆ្អែត ហីទន់អាក្បាលជង្គង់នេះអស់ ។ ដល់ទៅដល់ដើរទៅប្រាប់គ្នាវើយអញទន់ក្បាលជង្គង់អស់ហើយ ដល់ហូបបាយអីចឹង ។ ចោះធ្លាប់តែហូបបាយឆ្អែតដល់ហូបមិនឆ្អែតទន់ក្បាលជង្គង មានអីដើររក ។ ដល់ឃ្លានមែនទែនមានអី ដើររកតាចាំចម្ការបានល្ពៅប៉ុណ្ណេះដុតហូប ។

ប៊ុនថន ៖ បានអីលោកពូ?

ផាន ៖ ល្ពៅ ។

ប៊ុនថន ៖ ល្ពៅ?

ផាន ៖ ហ្នឹងហើយ ចេះតែដុតហូបទៅ វាអត់ហ្នឹង ។ ណ៎!

ប៊ុនថន ៖ កាលហ្នុងម៉េចគេផ្លាស់ពូមកហូបចល័តវិញ?

ផាន ៖ ទេ ខ្ញុំនៅជីកថ្មអីណោះហើយ ប៉ុនដល់ដឹងម៉េចបានគេអត់បើករបបឲ្យមកពីនោះ ក៏ឲ្យបើករបបចល័តនោណេះតែម្តង ។ របបចល័តដែលធានា របបចល័តដែលហូបឆ្អែត ហីគេឲ្យបបរព្រឹកបបរល្ងាចហូប ក៏បានពីរចានកំប៉ុត ទន់ក្បាលជង្គង់អស់ ។

ប៊ុនថន ៖ ម៉ាពេលពីរចាន?

ផាន ៖ ដល់ពេលឃ្លានដើររកតាមចាំចម្ការ ដល់ទៅណាល្ពៅគាត់បានទៅណា ដុតៗហូបកើត ។ អត់ឃ្លានមួយពេល ប៉ុន្តែវាមិនបានយូរខែទេ ។ វាចំនួនប្រហែលបាត់មួយខែ បានគេឲ្យខ្ញុំ

ទៅដឹក អាត្រាក់ពីរទៅដឹកខ្សាច់ឲ្យគេ គេបើករបបអង្ករពីនេះឲ្យទៅ ។ ឲ្យគេបើកអង្ករឲ្យទៅ ទៅបបរអង្ករគ្នាឯងគ្នាបួននាក់ អាត្រាក់ពីរគ្នាបួននាក់ហូបឆ្អែត ។ ដល់អាទឹកជន់មកត្រីវាឡើងតាមមុខលូនៅភ្នំលាប ទៅសុំសំណាញ់ប្រជាជនបង់ទៅបានត្រីហូប ៗ ឆ្អែតទៅ ។ បើនៅអាកន្លែងនេះហូបអត់ឆ្អែតទេ ប៉ះត្រង់ណាខ្ញុំហូបមិនឆ្អែតទៅ ខ្ញុំទៅដល់ស្ពានទីពីរចេះទៅ អារៀងឯងនិត ៗ កុហក់គេទៅថា អ្ហ៎ូ! ខ្ញុំមិនទាន់បានបាយទេ ។ ទាល់តែកុហកជងហ្នឹងអាសម័យនោះ ប្រាប់ថា ខ្ញុំមិនទាន់បានហូបបាយទេ ខ្ញុំថាខ្ញុំស្នើបាយជងចឹងទៅ ។ គេក៏រកឲ្យហើយ ឲ្យសេដ្ឋកិច្ចគេអ្នកដាំបាយ ។ ដាំឡើងមួយឆ្នាំងធំ ខ្ញុំតែពីរនាក់ប៉ុណ្ណោះ ប៉ុណ្ណាខ្ញុំពីរនាក់នេះឯង ។ ដាំឡើងមួយឆ្នាំងធំ អាអ្នកដាំនោះមានប្រុងដាំនេះទេ ដាំស៊ីខ្លួនវាផងចោះវាស៊ីមិនឆ្អែតដែល ។

ប៊ុនថន : ដាំទៅបានហូបដែរ?

ផាន : មើលទៅឆ្នាំដូចតូចណាស់ ដល់មើលអាឆ្នាំស្ពាន់ ព្រោះអត់សូវមានឆ្នាំងសដូចយើងអីទេ ។ យកអាឆ្នាំងស្ពាន់ធំ ៗ មើលអ្ហ៎ា! ដាក់តែមួយឆ្នាំងធំនឹកឃើញដាំកៀស ដាំកៀសខ្លួនវាផងអានេះឲ្យតែថាប្រធានវាឲ្យដាំបាយ គិតតែពីដាក់ហើយដើម្បីឲ្យសល់ទៅបានស៊ីខ្លួនឯងផង ។

ប៊ុនថន : បាទ! ពូស្នើប្រធានកងពូ?

ផាន : ហ្នឹងហើយ ស្នើប្រធានកងគេ ។

ប៊ុនថន : ស្ពានទីពីរនៅត្រពាំងថ្មនេះ?

ផាន : នៅជាប់ ខាងលិចស្ពានទីមួយ មួយ ស្ពានទីពីរ ប៉ុនវាឆ្ងាយគ្នាជីងប៉ុន្មានគីឡូ ឆ្ងាយពីគ្នាស្ពានទីពីរ ។

ប៊ុនថន : អង្គាល់នោះសាងសង់ហើយស្ពានទី?

ផាន : បាទ! សាងសង់មិនទាន់រួចទេនៅតែធ្វើ តែខ្ញុំដឹកថ្មទៅឲ្យគេ ។ ថ្ងៃណានេះទៅក៏ចេះតែកុហកគេ ប៉ុនមិនសូវហ៊ានកុហកញឹកញាប់ទេ ណ៎ា! យូរ ៗ ម្ដង ញឹកញាប់គេមិនជឿយើងទេ ។

ប៊ុនថន : ចោះម្ដាយចឹងបានម្ហូបអីទៅពូ បាយហ្នឹង?

ផាន : បាយបានអី បានតែប្រហុកឆ្ងាញ់ណាស់ មិនបានត្រីអី ។

ប៊ុនថន : ប្រហុកអីវិញពូ?

ផាន : អំបិល ប្រហុកអី អាហុកយើងធម្មតាហ្នឹង អាំង ដុតអីទៅឆ្ងាយណាស់ហើយ ។ ឲ្យតែបានបាយដូចបាននំសម័យហ្នុង ។ សម័យហ្នុងមិនបាច់ម្ហូបទេ ឲ្យតែបានបាយ ដូចបាននំហូបចឹងឯងជំនាន់នោះ ។

ប៊ុនថន : ចោះពូថាដឹកខ្សាច់ ដឹកយូរទេពូ?

ផាន : ខ្សាច់ដឹកជាមួយគ្នា ថ្ងៃណាគេឲ្យដឹកខ្សាច់ៗ ដឹកថ្មៗ ។

ប៊ុនថន : ដឹកខ្សាច់ជាមួយថ្ម?

ផាន : អ្ហើ!

ប៊ុនថន : ខ្សាច់ពីណាវិញពូ?

ផាន : ខ្សាច់ដឹកពីនោះហើយ ពីស្ទឹងទឹកជោរ ។ ចល័តអ្នកកើប គេកើបព្រនូកធំៗ ដូចព្រនូកចំបើងចឹង ដល់យើងទៅដឹកចឹងគ្រាន់ចល័តគេកើបឲ្យ ។ ដល់ខែវស្សាផងមុជយកនៅស្ទឹងឃើញចល័តមុជយកឡើងខ្សាច ។

ប៊ុនថន : មុជម៉េចបានៗព្រោះវានៅជ្រៅ?

ផាន : ដឹងមុជម៉េច ទឹកឡើងពេញមាត់ស្ទឹង ។ បើថាដាក់ទូកចេះ ដាក់ឬស្សីដោតចេះ មុជកើបរួចមកក៏ដាក់នឹងទូក ក៏ដឹកមកបានម្តងបន្តិចៗ ។ ខ្ញុំឈប់ចាំទំរាំបាននេះ ប៉ុនដឹកដែលបានពេញអាត្រាក់ ។ អ្ហា! អានោះសម្រាប់ខែវស្សា អ្ហា ។

ប៊ុនថន : ហីមុជចូលទឹកកើប?

ផាន : ខែប្រាំងវាកើបទុក ព្រនូកធំៗដឹកអស់ ។ អាខែវស្សាអស់ ក៏មុជក្នុងទឹកកើបសួរវាទៅថាពក់ វាអឺទៅឡើងឆ្ងាយ ដល់មើលមិនឃើញ ចឹងទៅឃើញអុំមកវិញ ដាក់ទូក ។

ប៊ុនថន : ស្ទឹងទឹកជោរ?

ផាន : បាទ! ឃើញបានមកក៏ឃើញមិនសូវច្រើនទេ គិតទៅទូកពីរបីទៅក៏ចេះទៅបីបួនដប់នាក់ទូកមួយគ្នាពីរបីនាក់ទៅ ។ យកមកទៅក៏ខ្ញុំ អានេះដែលបានពេញអាត្រាក់មកៗក៏ដឹកបណ្តោយ ហីគ្នាមុជយកពិបាកដែរខែវស្សា ។

ប៊ុនថន : ចឹងស្ពាននេះដឹក អ្ហឺ! គេសាងសង់ស្ពាននៅត្រពាំថ្មនេះដឹកមកពីរ ថ្មដឹកពីភ្នំលាប ហើយភ្នំត្រយ៉ូង?

ផាន : បាទ ភ្នំត្រយ៉ូង?

ប៊ុនថន : ហីខ្សាច់?

ផាន : ខ្សាច់ទឹកជោរផង ។

ប៊ុនថន : មានដឹកពីកន្លែងណាទៀតដេះពូ?

ផាន : ខ្សាច់បើត្រូវធ្វើអាល្អរបស់គេ គេដឹកពីទេ ពូថាខ្សាច់បាត់ដំបង ៗ ។ អាហ្នឹងគេដាក់អាកន្លែងត្រង់ណាដែលគេប្រើចាំបាច់ដាក់នោះ ។ មានអាខ្សាច់ល្អដែរតើ ប៉ុនដឹកមកពីឆ្ងាយ ។ អាខ្សាច់យើងចេះគេសម្រាប់រៀបចាក់គ្រឹះក្រោម ឬក៏រៀបបន្ទាយរៀបអីទៅ ។

ប៊ុនថន : ហីចឹងពូដឹកតាម៉ាកន្លែងទេ ដឹកទឹកដោរនឹងទេខ្សាច់ អត់មានទៅឡើងពីដឹកពីណាផ្សេងមកទេ?

ផាន : អត់ដែលបានដឹកពីណាមកទេ ខ្ញុំដឹកតែមួយកន្លែង ។

ប៊ុនថន : ប៉ុនពូដែរដូចថាប្រជុំទេ ដូចថាកងពូខាងកងអគ្គភាពអាត្រាក់ហ្នឹង?

ផាន : ប្រជុំយូរៗបានប្រជុំម្តង ។

ប៊ុនថន : ប៉ុន្មានខែពូ?

ផាន : បើសិនណាទៅពីរខែប្រជុំម្តង ។

ប៊ុនថន : ប្រជុំជាមួយពីណាវិញពូកាលនោះ?

ផាន : គេប្រជុំៗតែប្រធានកងគេ ប្រធានកងជាមួយប្រធានកង ។ ប្រជុំដូចយើងកូនចៅគេចឹងទៅ គេហៅយើងអង្គុយស្តាប់ហ្នឹងណា ។ ដល់ពេលតិទៀនម៉េច តាប្រធានកងគ្នាគេហ្នឹង ។

ប៊ុនថន : ប្រជុំនៅភ្នំលាបហ្នឹង?

ផាន : ទេប្រជុំនៅតាមកន្លែង ផ្ទះ ហ្នឹង ។ នៅនឹងកន្លែងផ្ទះ គេហៅដូចថាជុំគ្នា មិនបានទៅធ្វើការឯណាទៅ ។ ប្រជុំនោះ ប៉ុនកម្របានប្រជុំណាស់ យូរបានម្តង ។ យើងដែរចេះ មិនបាននិយាយទេ ចាំតែស្តាប់គេ ។ បើអាប្រជុំពងបីនាក់មានហើយ ប្រជុំបីនាក់គេហៅប្រធានពង់ៗ ។

ប៊ុនថន : គេហៅប្រធានអីវិញលោកពូ?

ផាន : គេហៅប្រធានពៗ ។ ប្រធានក្រុម មួយក្រុមវាមាន១០នាក់ ។ ហីប្រធានពងវាមាន៣នាក់ ។ បីនាក់ប្រធានម្នាក់ ។

ប៊ុនថន : ប្រធានពងម៉េចពូ?

ផាន : ពក ។

ប៊ុនថន : ប្រធានពក?

ផាន : គេហៅប្រធានពកៗ ។

ប៊ុនថន : ប្រធានពហីពូ?

ផាន ៈ ពក១ ។

ប៊ុនថន ៈ ប្រធានពួក?

ផាន ៈ ហ្នឹងហើយ ប្រធានពួក ។

ប៊ុនថន ៈ បាទប្រធានពួក ប្រធានពួកហ្នឹងបីនាក់?

ផាន ៈ អាហ្នឹងបីនាក់នោះហើយ ។

ប៊ុនថន ៈ ក្តាប់បីនាក់?

ផាន ៈ ក្តាប់បីនាក់ ក្តាប់បីនាក់ហ្នឹងឯង ។

ប៊ុនថន ៈ មួយនាក់ក្តាប់បីនាក់?

ផាន ៈ ទេ បីនាក់ក្តាប់ម្នាក់ មានម្នាក់អ្នកធ្វើប្រធាន ក្រុមបីនាក់ ។

ប៊ុនថន ៈ អ្ហូ! បាទ!

ផាន ៈ បើថាប្រធានក្រុមវាមាន១០នាក់ ម្នាក់ប្រធាន ។ អាប្រធានពួកនេះ បានប្រជុំញឹក បើប៉ះអាណាពាន អាមនុស្សណាពានដូចថាចូលខាងគេធ្ងន់ គេប្រាប់ថា អ្ហូ! បីថ្ងៃឲ្យប្រជុំម្តង១ បីថ្ងៃប្រជុំម្តង ដល់ទៅធុញ ខ្ញុំដល់ទៅចឹងធុញមែន ។

ប៊ុនថន ៈ ប្រជុំនិយាយពីអីវិញពូ ដល់ប្រជុំញាប់ពេកចឹង?

ផាន ៈ ដឹងនិយាយអីនេះផង និយាយថា អង្គការដាក់ទិសទៅត្រង់ណាអី យើងអត់រួញរា ។ ហឺ អង្គការដាក់ទិស ទោះបីតែមួយជំហានស្លាប់ មួយជំហានស្លាប់ក៏ដាច់ខាតប៉ុណ្ណោះឯង ។

ប៊ុនថន ៈ បាទ!

ផាន ៈ នេះបើខាងផ្នែកយោធាវិញ ប្រជុំអញ្ចោះឯង ដាក់ដូចថា ស្រេចអង្គការដាក់ទិស អត់មានខ្លាច អត់មានរួញរាទេ ទោះបីម៉ាជំហានស្លាប់ ម៉ាជំហានរស់ក៏ត្រូវតែទៅដែរ ដាច់ខាតថាទៅអត់មានខ្លាច ។

ប៊ុនថន ៈ បាទ!

ផាន ៈ សម័យដូចថា ធ្វើទាហានដូចថា យើងកាន់កាំភ្លើងបាញ់គ្នា សុទ្ធតែប្តេជ្ញាចឹងហើយ អត់មានថា អ្ហូ! រួញរាខ្លាចអីទេ ។

ប៊ុនថន ៈ ចោះពូដូចថាខាងផ្សេងដូចថា ដែកអីពូអត់មានដឹងថាដឹកមកពីណាទេ?

ផាន ៈ អត់ដឹងទេ ។ ខ្ញុំដឹកតែថ្ម ខ្សាច់ ។

ប៊ុនថន ៈ ត្រពាំងថ្មហ្នឹង ពេលដឹកមានទឹកមានអីដេះពូកាលហ្នឹង?

ផាន ៈ ទេ មិនដឹងផង ។

ប៊ុនថន ៖ ប៉ុន្តែឃើញដូចថាមានទឹកមានអីដេះ?

ផាន ៖ ពេលទៅដឹកហ្នឹង!

ប៊ុនថន ៖ ពេលគេលើកហ្នឹង កំពុងតែលើក ឧទាហរណ៍មានទឹក កន្លែងនោះជាវាលពូ?

ផាន ៖ វាល ។

ប៊ុនថន ៖ ចឹងមានទឹកអីប្រើប្រាស់ ហូបអី?

ផាន ៖ អ្ហ៎! មានហ្នឹងឯង ទឹកប្រើ ។ មានដើមមិញ មានអាថ្នល់មួយនោះទៅត្រូវចំអាស្ពានរាប ស្ពានចាស់ពីដើមមិញ ហីមានត្រពាំងមួយ ថ្មបាយក្រៀម ចេះអត់ទឹក សល់ទឹក ។ ដល់ពេលគេលើកចេះ គេលើកចំអាកណ្ដាលត្រពាំងនោះហើយ ត្រពាំងនោះខាងណេះថ្នល់ នោះខាងណេះថ្នល់ នៅចំកណ្ដាល លប់អាថ្មបាយក្រៀមអស់ ។ ស្ពានអាចាស់ពីដើមមិញ ដូចជាឆ្លងអាស្ពាននោះមិនដឹងដល់ពេលអាបាក់អស់ ។

ប៊ុនថន ៖ ស្ពានចាស់បុរាណ?

ផាន ៖ ហ្នឹងហើយចាស់បុរាណ ឃើញតែថ្មបាយក្រៀម ។

ប៊ុនថន ៖ ធំដេះស្ពានហ្នុង?

ផាន ៖ ហីវាបាក់ដីអស់ចោះ ដល់ពេលគេលើកអីអស់ចំអានោះហើយ ចំអាតួថ្នល់ ។

ប៊ុនថន ៖ ចឹងគេរើអាហ្នឹងចេញ?

ផាន ៖ ទេ ចាក់ដីពីលើៗ ចុះដល់គេចាក់ដីពីចឹងជើងវាធំ ជើងទំនប់វាធំ ។

ប៊ុនថន ៖ សព្វថ្ងៃនៅដេះពូ ស្ពានបុរាណ?

ផាន ៖ ទេ លប់អស់ ។ អត់មានឃើញថ្មទេ ចាក់ដីលប់ពីលើអស់ ។ គេធ្វើចំអាស្ពាននោះឯង ក៏ចាក់លប់ពីលើអស់ ។ គេសព្វថ្ងៃ គេកាន់តែពង្រីកទៀតហើយ ពង្រីកជើងក្រោមទៀត ។

ប៊ុនថន ៖ ហីចោះពូ នេះដេះពូ ដូចអ្ហ៊ី! ហ្នុងគេហៅវិញពូដូចថាគេហៅ ដូចគេបង្កើតឥឡូវជាភូមិ ឬជាសហរណ៍ជាអីពូ?

ផាន ៖ ភូមិ ។ ពីដើមមិញ ភូមិគេទល់សព្វថ្ងៃ ភូមិភ្នំលាប ។

ប៊ុនថន ៖ បាទ ភូមិភ្នំលាប?

ផាន ៖ បាទ ភូមិភ្នំលាប ភូមិភ្នំត្រយ៉ូង ប៉ុនគេហៅពេលសព្វថ្ងៃភូមិភ្នំលាបតែប៉ុណ្ណោះ ។ ដល់ទៅដល់ទៅនោះវាមានភូមិដូចយើងអាវែង ភូមិកណ្ដាលអីចេះ ហើយឈ្មោះសព្វថ្ងៃឈ្មោះតាវែង តែមួយ ។

ប៊ុនថន ៖ ចឹងអន្តភាពពូ អន្តភាពសហជីព អន្តភាពអាត្រាក់ហ្នឹងនៅដាច់ដោយឡែកពីប្រជាជននៅហ្នុង?

ផាន ៖ ដាក់ដោយឡែក ។

ប៊ុនថន ៖ ប៉ុននៅជិតគ្នាពូ?

ផាន ៖ ជិតគ្នា ។

ប៊ុនថន ៖ ចឹងពូនៅហ្នុងមានស្គាល់យាយ ចែម អីទេ?

ផាន ៖ ស្គាល់តើ ។

ប៊ុនថន ៖ អ្ហូ! ស្គាល់គាត់ដែរ?

ផាន ៖ ដល់ពេលគេចាប់តា ដាល ទៅយាយ ចែម នោះហើយប្រធាន ។

ប៊ុនថន ៖ អ្ហូ!

ផាន ៖ ចាប់យកតា ដាល ទៅណ៎ា! យាយ ចែម នោះប្រធានធំជាងគេ ។

ប៊ុនថន ៖ តាហ្នុងកាលហ្នឹងគាត់នៅណាវិញ?

ផាន ៖ តា ដាល ដែលថានេះ ដែលថាកូនតា ញឹម ។

ប៊ុនថន ៖ កូនតា ញឹម ។ មុនគាត់នៅភ្នំលាប?

ផាន ៖ ទេ គាត់នៅគាឯស្វាយ ។

ប៊ុនថន ៖ ប៉ុនគាត់តួនាទីអីវិញកាលហ្នុង?

ផាន ៖ កាលនោះគាត់ដែលអត់តា ហឹង ទៅគាត់ឡើង តាដាល ហ្នឹងធំ ។

ប៊ុនថន ៖ ឡើងតា ដាល!

ផាន ៖ អត់តា ដាល ទៀត មានពីណា មានតែយាយ ចែម ។

ប៊ុនថន ៖ យាយ ចែម?

ផាន ៖ បាទ យាយចែមគាត់នៅភ្នំលាបហ្នឹងហើយ ។ ដឹងតែយាយ ចែម គាត់នៅភ្នំលាបនេះ ។

ប៊ុនថន ៖ កាលហ្នុងយាយ ចែម គាត់មកឆ្នាំប៉ុន្មាន ពូមានដឹងទេពូនៅហ្នុង ប្រហែលឆ្នាំប៉ុន្មាន?

ផាន ៖ ទេ ខ្ញុំឃើញអាចុងឆ្នាំវៀតណាមចូល ។

ប៊ុនថន ៖ ឆ្នាំ១៩៧៨?

ផាន ៖ ឆ្នាំ៧៨-៧៩ ។ ៧៨ ។

ប៊ុនថន ៖ ប៉ុនកាលពូមកនៅ អំឡុងពេលពូនៅភ្នំលាបហ្នឹងមានឃើញគាត់ទៅនៅហ្នុង?

ផាន ៖ គាត់នៅអីនោះតើ ។

ប៊ុនថន : នៅនោះ គាត់ទៅឆ្នាំប៉ុន្មានដំបូង?

ផាន : ទេគាត់ទៅមុនខ្ញុំទៀត នៅមុនខ្ញុំទៅទៀត។ គាត់មកនៅយូរហើយយាយ ចែម នោះ។ យូរដែររយៈ ៧៧ អីហ្នឹងឯង។

ប៊ុនថន : ពូទៅចឹងឆ្នាំប៉ុន្មាន ពូទៅភ្នំលាប?

ផាន : ខ្ញុំទៅយូរដែរ ប៉ុនខ្ញុំទៅមកៗ។ កាលដែលខ្ញុំទៅនោះ គាត់អត់ទាន់ទៅទេ ប៉ុនកាលនោះមិនដឹង៧០ប៉ុន្មានទេ។ ដល់ក្រោយទៀត បានដូចថាខ្ញុំទៅនៅមួយសារទៅ ដឹករួចចេះទៅខ្ញុំចុះទៅភ្ជួរ។ ណា៎!

ប៊ុនថន : ភ្ជួរ?

ផាន : ដល់ក្រោយមកទៀត បានគេឲ្យខ្ញុំចុះទៅដឹកទៀតទៅ។

ប៊ុនថន : អ្ហូ!

ផាន : អត់មាននៅនេះម៉ាកន្លែង អ្ហា!

ប៊ុនថន : ចឹងពូផ្លាស់ចេញទៅភ្ជួរទៀត?

ផាន : បាទ ភ្ជួរផង ដល់ឈប់ភ្ជួរទៅដឹកថ្មផងអញ្ចោះហើយ ស្រេចគេប្រើ។

ប៊ុនថន : ចឹងម៉ាវគ្គពូទៅដំបូងគេ អត់ទាន់មានមកទេ?

ផាន : កាលនោះគាត់អត់ទាន់មានមកទេ។ នៅៗអាជិតចុងក្រោយ អា៧៧នោះឯង។

ប៊ុនថន : ៧៧-៧៨?

ផាន : ចុង៧៧។

ប៊ុនថន : ពូចេញទៅភ្ជួររយៈពេលប៉ុន្មានពូ?

ផាន : ខ្ញុំភ្ជួរដូចថា ម៉ារដូវៗភ្ជួរ ភ្ជួរស្រែ។

ប៊ុនថន : ម៉ារដូវ៦ខែអីចឹងពូ?

ផាន : បាទ ម៉ារដូវ។

ប៊ុនថន : ហីបានត្រឡប់ទៅកន្លែងដឹកថ្មហ្នឹងវិញ?

ផាន : ឡើងមកកន្លែងចឹងទៅ ឡើងមកកន្លែងចេះទៅ។ ដល់ក្រោយទៀត គេឲ្យដឹកថ្មទៅទៀតដល់យូរដល់ក្រោយមក មានអាទៅភ្ជួរស្រែមួយចំនួន អានៅដឹកថ្មនោះមួយចំនួន ម៉ាកងដឹកថ្មឲ្យគេ អត់បានទៅភ្ជួរទេក្រោយមក។

ប៊ុនថន : ចឹងពូនៅខាងដឹកថ្មវិញ អ្នកផ្សេងគេនៅ?

ផាន ៖ បាទ អត់បានទៅចូល នៅដឹកថ្ម។ ដល់ដែលខ្ញុំឃើញគាត់ច្បាស់មែនទែនហ្នឹង ខ្ញុំឃើញគាត់ច្បាស់៧៨ ។

ប៊ុនថន ៖ ដើមក៏ចុងពួ ក៏កណ្តាល?

ផាន ៖ មិនមែនចុងទេ ប៉ុនឃើញយូរគ្រាន់ហើយ មុនវៀតណាមចូល ។ ពេលវៀតណាមចូល វៀតណាមចូលគាត់នៅនោះដែល ថ្ងៃដែលគេដ្ឋើលគាត់ក៏នៅនោះ ។

ប៊ុនថន ៖ គាត់តួនាទីអីវិញកាលហ្នុង?

ផាន ៖ កាលនោះគាត់ធំ ដល់អស់អ្នកធំៗអស់ហើយ មានតែគាត់ធំជាងគេ ដូចថាម៉ាតំបន់៥នេះ ដឹងថាគាត់លើគេ ។

ប៊ុនថន ៖ ម៉េចពូដឹងគាត់ដូចថាប្រធាន ដូចថាមានអ្នក?

ផាន ៖ ដឹងពូតែថាគាត់ធំៗជាងតា ពល ជាងតា វ៉ាល់ តាអីទៀត ។

ប៊ុនថន ៖ អ្ហូ!

ផាន ៖ ដូចថាគាត់ប្រធានលើពីនោះទៀត ។

ប៊ុនថន ៖ បាទ គាត់នៅជិតកន្លែងពូដែរនៅភ្នំលាប?

ផាន ៖ នៅជិតគ្នាតើ គាត់នៅក្នុងភូមិ ខ្ញុំនៅជើងភូមិ ។

ប៊ុនថន ៖ ប្រហែលប៉ុន្មាន?

ផាន ៖ ដូចថាភូមិចេះ ខ្ញុំនៅជាយ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ពីដើមមិញខ្ញុំនៅភ្នំត្រយ៉ូង ដល់អ្នកត្រយ៉ូងគេដាក់ទោសច្រើនពេក ដល់អ្នកទោសភ្នំត្រយ៉ូងច្រើនទៅ ខ្ញុំអត់នៅទៅ ខ្ញុំឲ្យមកនៅផ្ទះភូមិគេ ។

ប៊ុនថន ៖ ដាក់ទោសម៉េចវិញពូភ្នំត្រយ៉ូង?

ផាន ៖ ភ្នំត្រយ៉ូងគេដាក់អ្នកទោស ដល់ពីដើមមិញគេមិនដែលដាក់ទេ ។ ខ្ញុំទៅមកមុនគេដាក់អ្នកទោសនេះហើយ ក្រោយមកគេបង្កើតអ្នកទោសហ្នឹងណា៎!

ប៊ុនថន ៖ បាទ!

ផាន ៖ គេដាក់អ្នកទោស គេយកអ្នកទោសទៅដាក់ ។ ដល់គេដាក់រួច មានគេធ្វើផ្ទះធ្វើអីនៅផង ។

ប៊ុនថន ៖ បាទ!

ផាន ៖ អ្នកណាមានទោសមានអីក៏ដឹកដាក់នោះហើយ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដាក់រាប់រយយ៉ាងតិច ។

ប៊ុនថន ៖ បាទ!

ផាន ៖ ច្រើនដែរ មនុស្សវាច្រើនៗពេកទៅ ខ្ញុំថយមក ចោះបើនៅមិនកើតបៀតគេ ។ ខ្ញុំថយមកនៅភូមិភ្នំលាប ។

ប៊ុនថន ៖ ភូមិភ្នំលាប?

ផាន ៖ បាននៅអាស្រេះជិតថ្នល់ ។

ប៊ុនថន ៖ ពួអ្នកទោសភាគច្រើនធ្វើអីវិញពី ធ្វើអីខុសពូ?

ផាន ៖ ខុសមិនដឹងទេ ធ្វើវាខុសតាមសហករណ៍នេះហើយ ហើយគេដឹកទៅ ។

ប៊ុនថន ៖ បាទ អ្នកៗ?

ផាន ៖ ហើយដល់កន្លែងនោះគេឲ្យវាយថ្ម ដកចល័តចេញ ។ ចល័តទៅនៅវាយថ្មនោះ គេដកចេញ ឲ្យអ្នកទោសវាយថ្មម្ដង ។

ប៊ុនថន ៖ បាទ ឲ្យអ្នកទោស ។ អ្នកទោសហ្នឹងយកដកពីកងចល័តទៅហ្នឹងពូ អ្នកទោសសុទ្ធអ្នកមកពីកងចល័ត?

ផាន ៖ ទេ តាមសហករណ៍ ។

ប៊ុនថន ៖ តាមសហរណ៍?

ផាន ៖ ទាំងប្ដីទាំងប្រពន្ធ ។ បាទ មកជួបទាំងប្ដី មកជួបទាំងប្រពន្ធទាំងប្ដី ។

ប៊ុនថន ៖ ច្រើនទេពូ?

ផាន ៖ ច្រើនដែរ ឡើងគេធ្វើផ្ទះឲ្យនៅ ផ្ទះគេមួយៗគេនាំឲ្យនៅ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ខ្ញុំមិនបានចូលផងផ្ទះ រាប់ពាន់ដឹងនេះ ។

ប៊ុនថន ៖ រាប់ពាន់នាក់ពូ?

ផាន ៖ ដល់នេះធ្វើផ្ទះឲ្យនៅ ។

ប៊ុនថន ៖ ពីណាអ្នកគ្រប់គ្រងទៅ?

ផាន ៖ អ្នកគ្រប់គ្រងនោះឈ្មោះតា ខៀន ។

ប៊ុនថន ៖ តាអីវិញពូ?

ផាន ៖ ខៀន ។

ប៊ុនថន ៖ តា សៀន?

ផាន ៖ គាត់ហ្នឹងនិរតី ។

ប៊ុនថន ៖ តា សឿន មកពីនិរតីដែរ?

ផាន ៖ តា ឌឿន តាប៉ែត ។

ប៊ុនថន ៖ តា ឌឿន តាប៉ែត?

ផាន ៖ តាប៉េតៗ ឈ្មោះតា ប៉ែត ។

ប៊ុនថន ៖ តាប៉ែត?

ផាន ៖ បាទ!

ប៊ុនថន ៖ បាទ ពីនាក់នោះគាត់គ្រប់គ្រងអ្នកទោសមកពីសហករណ៍ហ្នឹង?

ផាន ៖ គាត់គ្រប់គ្រងអ្នកទោស ។

ប៊ុនថន ៖ បាទ ហីអ្នកទោសហ្នឹង អំមិញគាត់ធ្វើខុសអីវិញភាគច្រើនអឺ?

ផាន ៖ មិនដឹងដែរ នៅតាមសហករណ៍គេចាប់ទៅ ខ្ញុំមិនដឹងច្បាស់ ។ ខ្ញុំនៅឃើញដឹកគាត់ៗ កាន់តែច្រើនឡើងៗ ។

ប៊ុនថន ៖ ចឹងដំបូងខាងចល័តទេអ្នកវៃថ្មហ្នឹង ពេលក្រោយមកដកចល័តចេញ យកអ្នកទោសមកម្ដង?

ផាន ៖ យកអ្នកទោស ដល់អ្នកទោសមកច្រើន ឲ្យអ្នកទោសវាយ ដកចល័តចេញ ។

ប៊ុនថន ៖ អ្នកទោសដូចកំណត់ឲ្យវៃទេពូ ឲ្យវៃប៉ុន្មានៗអីចឹង?

ផាន ៖ អ្ហូ! មានដឹង ខ្ញុំមិនសូវដឹងផង ដឹងប៉ុនដឹងថាវៃថ្ម។ ខ្ញុំខស្សាហ៍ទៅ ក៏អ្នកទោសដាក់បោះថ្មលើអាត្រាក់ ។

ប៊ុនថន ៖ ម៉េចបានពូដឹងពូ សួរគេ?

ផាន ៖ អ្ហា!

ប៊ុនថន ៖ ម៉េចបានពូដឹងថាពួកហ្នឹងជាអ្នកទោស?

ផាន ៖ អ្ហូ! បោះនោះមិនដឹងដែលនៅនោះមិនដឹង ខ្ញុំធ្លាប់នៅនោះឯង ដល់ខ្ញុំនៅនោះពីដើមមិញដល់អ្នកទោសច្រើនថយទៅឲ្យហួស ។

ប៊ុនថន ៖ បោះមាននេះអីពូ?

ផាន ៖ ឲ្យតែអ្នកនោះហើយ អ្នកទោសទាំងអស់ ម៉ាបរិវេណនោះសុទ្ធតែអ្នកទោស ។

ប៊ុនថន ៖ បាទ ដូចថាគេមានទាហានយាម មានអីដេះពូ?

ផាន ៖ មានតែឈ្លបគេ ។

ប៊ុនថន ៖ ឈ្លប?

ផាន ៖ ឈ្លបគេឃើញមកកាន់កាវែវ ។ កាន់កាវែវ កាន់កាំបិតអីណា ក្រោយយូរមក បានមាន កាំភ្លើង ។

ប៊ុនថន ៖ អ្ហ៎! ច្រើនទេពូ?

ផាន ៖ នៅប្រហែលជាច្រើនប៉ុន្មានទេ ប្រហែលបៀតណា៨-១០នាក់ ។ ហីឈ្លបតែពួកគាប៉ែត ពួកពាយ័ព្យយើង ប៉ុន្តែអ្នកក្តាប់និរតី ។

ប៊ុនថន ៖ ចោះអ្នកទោសមានយកទៅ ដូចថាដាក់ទោស ដាក់ច្រវ៉ាក់ ដាក់ខ្នោះអីទេពូ នៅកន្លែង ហ្នុង?

ផាន ៖ ខ្ញុំអត់ដឹងទេ បើអ្នកទោសធ្ងន់មិនដឹងគេដាក់មិនដាក់ ឃើញអ្នកទោសស្រាលៗអាខ្លះគេ ឲ្យកាប់ដី ខ្លះក៏រែថ្មៗ បាទ ត្រង់អ្នកទោសធ្ងន់ៗមិនដឹងសោះ ចុះកន្លែងគេចោះគេលាក់ ការណ៍ដែរ ។

ប៊ុនថន ៖ ប៉ុនពូថាធ្វើផ្ទះឲ្យនៅច្រើននោះពូមុនឃើញ?

ផាន ៖ ចោះវានៅដែរ ធ្វើឡើងដូចផ្ទះគំរូចឹង ។ ទៅលើក អត់មានលើក លើកនៅនឹងដីឡូអីចឹង ។

ប៊ុនថន ៖ ចោះមានយកទៅវាយចោលអីទេពូ?

ផាន ៖ អាកន្លែងផ្ទះមួយនោះវែង សម្រាប់គេដឹកទៅដល់ដាក់ មិនទាន់មានផ្ទះនៅ នៅអាផ្ទះវែង នោះ ។

ប៊ុនថន ៖ បាទ មានឈឺមានអីដេះពូ?

ផាន ៖ ដឹងឈឺយ៉ាងណា មិនបាននៅជាមួយទេ អ្ហ៎លេងអត់បានអីចឹង អត់ឃ្លានៗ នរណាទោស ធ្ងន់បន្តិចគេវាយចោល ។

ប៊ុនថន ៖ បាទ ចុះមានយកទៅវាយចោលដែរពូ?

ផាន ៖ មានអី បើខ្ញុំមួយថ្ងៃៗមិនបាននៅជាមួយគេផង ធ្វើម៉េចដឹង បើយើងថាស្មានទៅអត់ កើត ។

ប៊ុនថន ៖ បាទ ចុះពូថាដូរពីភ្នំត្រយ៉ូង មកភ្នំលាបវិញពូដោយសារអ្នកទោស?

ផាន ៖ ខ្ញុំមកនៅឯភូមិដោយសារអ្នកទោសវាច្រើន ។

ប៊ុនថន ៖ ម៉េចពូបានដូរចឹងពូ ដូចថា?

ផាន ៖ ចុះដូចថាខ្ញុំនៅកន្លែងនេះហើយ ដល់អ្នកទោសទៅនៅកន្លែងនោះឯង នោះហើយរបស់ខ្ញុំហើយយើងគេ ដឹងថាគេនៅច្រើនៗទៅ យើងមិនផាស់ៗខ្លួនយើង។ ចេញខ្លួនយើងមិនបានប្រាប់ឲ្យចេញ។

ប៊ុនថន ៖ ប៉ុន្មាននាក់កាលហ្នឹង?

ផាន ៖ ខ្ញុំនៅប្រហែល៨, ១០, ២០នាក់។

ប៊ុនថន ៖ ដូរទាំងអស់មក ដូរម៉ាក្រុម?

ផាន ៖ លើករោងនៅៗផ្សេង លើករោងនៅឆ្ងាយពីគេទៅ ទៅបៀតភូមិ ក្នុងភូមិ ជើងភូមិទៀត។

ប៊ុនថន ៖ បាទ ហើយាយ ចែម នៅជិតហ្នឹងដែរ?

ផាន ៖ យាយ ចែម នៅឯភូមិ។

ប៊ុនថន ៖ ក្នុងភូមិហ្នឹង?

ផាន ៖ បាទ យាយ ចែម មានកូនង៉ាទៀតតើ។ ថ្ងៃដែលវៀតណាមចូល មុនថ្ងៃវៀតណាមចូលមួយថ្ងៃនៅភ្លើង។

ប៊ុនថន ៖ អ្ហ៎!

ផាន ៖ ចាស់ហើយមានកូនង៉ា។ ថ្ងៃវៀតណាមចូល ដល់ព្រឹកឡើងនិរសារឌុបគាត់បីកូនង៉ា។

ប៊ុនថន ៖ និរសារឌុបគាត់បី?

ផាន ៖ គាត់បីកូន។

ប៊ុនថន ៖ ចោះយកអីឌុបគាត់ ម៉ូតូ ឬមួយឡាន?

ផាន ៖ ម៉ូតូហ្នឹង។ កំពុងតែរត់វៀតណាមចូល គេចេញអស់ហើយ។ ប្រជាជនយកទៅឲ្យជួយប្រូតស្រូវ តាមប្រូតមិនអស់ទេ យកទៅឲ្យជួយប្រូតស្រូវ ក៏ប្រជាជនគ្នាចេញទាំងល្ងាចដេញចេញទាំងល្ងាច។ នរណាមិនមានរទេះក៏រែករណេងទីងទោង ខ្ញុំដេកនោះហើយ តែដល់យប់ឡើងបានរត់មកអានេះ ចោះកាំភ្លើងមកពីកើតគ្រឺលៗ វៀតណាមបាញ់ចូល។ ហីព្រឹកឡើង ខ្ញុំរត់ដែរហ្នឹង ហីចូលតាមនោះឯង មកពីសៀមរាប។

ប៊ុនថន ៖ ប៉ុន្មាន យាយ ចែម កូនគាត់ប៉ុន្មាននាក់?

ផាន ៖ អត់ដឹងថាប៉ុន្មានទេ។

ប៊ុនថន ៖ ចុះពូឃើញគាត់នៅភ្លើង នៅបីកូន?

ផាន ៖ ហ្នឹងហើយ អានេះបីតែកូនង៉ាមួយ និរសារជូនកាលហ្នុងប្រធានសហករណ៍ ប្រធានភូមិ ម៉ូតូគេពីរបី ។

ប៊ុនថន ៖ បាទ!

ផាន ៖ ប្រជាជនចេញពីល្វាចអស់ហើយ គេឲ្យចេញ កុហកថាប្រូតស្រូវ... ។

ប៊ុនថន ៖ បាទ ហីចុះគ្រួសារគាត់ពីណាវិញពូ?

ផាន ៖ គ្រួសារគាត់ឈ្មោះ តាញ៉ែនៗ ។

ប៊ុនថន ៖ តាញ៉ែន?

ផាន ៖ តាញ៉ែន ។

ប៊ុនថន ៖ តាញ៉ែន?

ផាន ៖ ញ៉ែនៗដេះ ដឹងឈ្មោះទេ?

ប៊ុនថន ៖ ញ៉ែន ញដាក់ស្រះអេ នឹងញ?

ផាន ៖ អ្ហឺ! តាញ៉ែនៗ ដឹង... ។ ដូចថាយើងមិនបាននៅជាមួយគាត់ទេ គ្រាន់តែគេថាទេ ប្ដីគាត់ឈ្មោះ ញ៉ែន ។

ប៊ុនថន ៖ តាញ៉ែន គាត់នេះទេពូ គាត់ធ្វើការដែរ?

ផាន ៖ ធ្វើការដូចតែគាត់ចឹង ។

ប៊ុនថន ៖ គាត់ខាងអីវិញ គាត់ធំដូចប្រពន្ធគាត់ទេ?

ផាន ៖ ធំដូចតែគ្នា ប៉ុនដឹងកាន់ការអី ។ ប្រពន្ធធ្វើធំហើយ សម័យនោះធ្វើធំដូចគ្នា ។

ប៊ុនថន ៖ គាត់ខស្សាហ៍ទៅនេះទេ ទៅកន្លែងពូអីពូ?

ផាន ៖ ទេ មិនដែលបានទាក់ទងទេ ។

ប៊ុនថន ៖ មិនដែលបានទាក់ទងទេ?

ផាន ៖ ស្គាល់ គ្រាន់តែឃើញគាត់ដើរមើល... ស្គាល់ ។

ប៊ុនថន ៖ ប៉ុនដែលជួបគាត់ទេ ដូចថាគាត់ដើរអីជួបចឹងនៅជិតភូមិគ្នាអាច?

ផាន ៖ ទេជួបៗ ប៉ុនមិនដែលបាននិយាយគ្នាផង ។

ប៊ុនថន ៖ ជួបនៅណាវិញ ជួបផ្ទះគាត់ ក៏ជួននៅកន្លែងបងពូ?

ផាន ៖ ជួបនឹង ឃើញគាត់ដើរអីទៅ ឃើញមុខគាត់ ។ មួងហ្នឹង ខ្ញុំមកពីណាទេ អាថ្ងៃដែលវៀតណាមចូលហើយ យោធាបាក់ទ័ពមកពីណាទេ ឃើញបើកឡានអាសេអ៊ុមសេមក ឃើញគាត់ជិះក្នុងឡាន ។ ហីទៅដល់ស្អែកឡើង ក៏នេះពុស្សូរកាំភ្លើងមកពីនោះ ។

ប៊ុនថន : គាត់ជិះឡានសេអុីមសេ ប៉ុនជិះម៉េចពូថា?

ផាន : ជិះមកផ្ទះគាត់ ។

ប៊ុនថន : ឡានហ្នឹង?

ផាន : អានោះមិនទាន់ផ្អើល ។

ប៊ុនថន : បាទ!

ផាន : អានោះមិនទាន់ផ្អើលទេ នៅភ្នំលាប ប៉ុនអាយោធាដែលជិះជាមួយហ្នឹងវាបាក់ទ័ពមកពីណាដឹង ។

ប៊ុនថន : ជិះជាមួយគាត់ ឬគាត់នៅផ្ទះហើយយោធាជិះមក?

ផាន : ទេយោធានានោះជិះឡានជាមួយគាត់ ។

ប៊ុនថន : ហីគាត់ថាគាត់មានកូនចៅដែរពូ?

ផាន : អ្ហ៎! អានោះគាត់នៅក្មេងទេ ។ ដល់ថ្ងៃរត់នោះ មុនគាត់នៅក្មេង ។

ប៊ុនថន : មុនហ្នឹងទៀត?

ផាន : អ្ហឺ!

ប៊ុនថន : ចោះគាត់ម៉េចដែរ ដូចថានៅជិតភូមិជាមួយគ្នាចឹង?

ផាន : ដឹង ដែលចេញចូលចឹងទៅដឹងណា ដល់ទៅគេចង់ទាំងអាតូចទាំងអាគាច ដល់ដូចថាការងារយើងវាផ្សេង គាត់ផ្សេងទៅ ដូចថា ប្រជាជនគេនៅនោះបានដឹងគាត់ស្លូតគាត់កាច់ ហីខ្ញុំអត្តភាពវាផ្សេងគ្នា ។

ប៊ុនថន : បាទ!

ផាន : ទាល់តែគាត់មានក្តាប់ខ្ញុំ គាត់ផ្សេង ។ ទោះបីតែគាត់កាច ក៏គាត់គ្រាន់តែប្រាប់អាណាម្នាក់ទៅនេះទៅ ទៅបញ្ជា គាត់ជាអ្នកបញ្ជា ។ បាទ យើងខ្លាចគាត់តែចោះហើយ ដូចខ្លាច ។

ប៊ុនថន : ម៉េចបានខ្លាច បើពូនៅអត្តភាពផ្សេង?

ផាន : ចោះបើគេធំ ធំជាងអ្នកក្តាប់ខ្ញុំទៀត គេធំជាង ចេះតែខ្លាចគេ បញ្ជាតែមួយម៉ាត់នោះឯង ។

ប៊ុនថន : នៅក្នុងភូមិ នៅភូមិភ្នំលាបហ្នឹង ជិតផ្ទះគាត់មានផ្ទះអ្នកភូមិមានផ្ទះប្រជាជនអីនៅហ្នឹងទេពូ?

ផាន : មានតើ ជិតៗគ្នា ។ គាត់នៅផ្ទះប្រជាជនពីដើម ។ ផ្ទះណាស្អាតធំៗចឹង គាត់ឡើងនៅម្ចាស់គេដឹងទៅណា ។

ប៊ុនថន :	ប៉ុនប្រជាជន ដូច អ្ហ៊ា! នៅក្នុងភូមិហ្នឹងជាមួយគាត់ដេះ ក៏អត់ទេ?

ផាន :	នៅជាមួយ ។

ប៊ុនថន :	តែកម្មាភិបាល?

ផាន :	អ្ហ៊ើ! កម្មាភិបាលផង ប្រជាជនក៏នៅនោះដែរ ។

ប៊ុនថន :	ចោះពូអត់ដែលបានផ្ទះគាត់លេងទេ ដូចថា ដើរពេលទំនេរអត់មានការចឹងដើរលេង?

ផាន :	តែហ៊ានទៅ ដែលហ៊ានដើរទៅលេងទេ ។

ប៊ុនថន :	ចុះក្នុងភូមិពូដែលដែរស្គាល់អីដេះ?

ផាន :	ក្នុងភូមិខ្ញុំក៏មិនដែរបានដើរ ។ មិនដែលបានដើរទេ ។

ប៊ុនថន :	ដូចថាទំនេរ ដូចថាឥឡូវយើងដើរទៅផ្ទះគេផ្សេងៗ?

ផាន :	នោះហើយ មិនដែលបានដើរលេងទេ ។

ប៊ុនថន :	ម៉េចវិញពូ?

ផាន :	វាមិនសូវហ៊ានដើរហ្នឹង ។ សម័យហ្នឹងដែលសូវហ៊ានដើរ ដូចយើងសព្វថ្ងៃ ទំនេរទៅផ្ទះនេះ ផ្ទះនោះ គ្រប់តែកន្លែង ។

ប៊ុនថន :	ហីពូ ពូនិយាយមិញថាចាប់ប្រធានពូ តាចយ ហ្នឹង ចាប់គាត់ហើយពីណាមកជំនួសគាត់ម្តង?

ផាន :	វាចាត់តាំងនេះអាអ្នកតូចៗ ធ្វើប្រធានកង ឲ្យក្តាប់ជំនួសប្រធានកាលចាប់ ។ កាលមកចាប់ទាហាន និងពេទ្យ បាននិរតីចូលមកឋានៈគាត់ឈ្មោះតា រិនៗ ។ ដល់បាត់តា រិន ហ្នឹងទៀតតា រិន តា រិន ហ្នឹងឲ្យកូន ដូចថានិរសារគាត់ឲ្យចុះតាមអង្គភាពនីមួយៗ ។ យូរៗ បាត់តា រិន បាត់អីនោះទៀតទៅ នៅយាយ ចែម គាត់នៅវៀតណាមមកជាប់ទៅ ។

ប៊ុនថន :	នៅយាយ ចែម ហីយាយ ចែម ហ្នឹងក្តាប់លើអង្គភាពពូទៀត?

ផាន :	ក្តាប់រួមទាំងអស់ មាននរណាធំទៀតអស់ ។

ប៊ុនថន :	បាទ!

ផាន :	អាសម័យនោះដឹងម៉េចទេ ។

ប៊ុនថន :	ចោះពូថាបាត់ ជាល នោះពីណាឡើងជំនួសវិញ ថាតា ពល តាអីណា?

ផាន :	ទេ ដល់អត់តា ជាល ទៅ ។ កាលហ្នុងមិនដឹងអ្នកណាទេ ។

ប៊ុនថន :	ពូថាមានឈ្មោះ ពល ឈ្មោះអី?

ផាន :	អ្ហ៊ា!

ប៊ុនថន ៖ មានឈ្មោះ តាពល ឈ្មោះអីណានោះ?

ផាន ៖ អ៊ូ! ឈ្មោះតា ពល ឈ្មោះអីនោះ គាត់ក្ដាប់នៅនេះផ្សេងៗ គាត់ក្ដាប់ចល័ត ក្ដាប់អីនោះៗ បើដូចតា ផាល គាត់ធ្វើធំជាងនោះទៀតៗ បាត់តា ផាល ទៅមានតែយាយ ចែម ហ្នឹងហើយៗ កាលតា ផាល នៅ ជាមួយនិរតីអត់សូវត្រូវគ្នាទេ ណា៎!

ប៊ុនថន ៖ បាទ ម៉េចវិញ?

ផាន ៖ រឿងយើងទំនាស់គ្នាៗ គេកំពុងតាមដានពាយ័ព្យយើង ពាយ័ព្យយើងចាប់មេៗអស់ហើយៗ

ប៊ុនថន ៖ បាទ!

ផាន ៖ ហីតា ផាល ធ្វើធំបឹង ដល់គេមកគេតាមដានៗ និរតីកាន់តែច្រើន និរតីកាន់តែច្រើនៗទៅ ហើយពាយ័ព្យយើងខ្វាចគេ គេចាប់ចង់អស់ហើយៗ គេឲ្យមកទៀត ចាប់ តាផាលទៀត អស់ដើងៗ សុទ្ធតែពួកនិរតីទាំងអស់ ធ្វើការយូរៗទៅទទួលបញ្ជាគេទាំងអស់ចោះគេធំហើយៗ

ប៊ុនថន ៖ ចោះពូនៅភ្នំលាបរហូតដល់៧៩ពូ?

ផាន ៖ បាទ ពេលរត់យួនៗ

ប៊ុនថន ៖ យាយ ចែម យាយអីហ្នឹង?

ផាន ៖ នោះហើយៗ ខ្ញុំនៅរហូតដល់យួនចូល?

ប៊ុនថន ៖ ចេញពីហ្នុងទៅណា ពូត្រឡប់មកភូមិវិញ?

ផាន ៖ ដល់ពេលយួនចូល ខ្ញុំរត់ទៅនោះឯង ទៅពង្រ ទៅគង់សៀម បើកអាត្រាក់រត់ទៅណោះហើយៗ យាយ ចែម នោះក៏រត់ទៅទាំងអស់គ្នាៗ មួយផ្នែកជាប់ស្ទឹង មកជាប់ជប់នេះផ្នែកទាំងអស់ពួកនិរតីៗ អ្នកក្ដាប់ ក្ដាប់អ្នកដែលរត់ៗ

ប៊ុនថន ៖ បាទ!

ផាន ៖ ហើយបញ្ជូនមកឲ្យដឹកស្រូវ ឲ្យខ្ញុំមកដឹកស្រូវទៀតៗ ខ្ញុំមកដល់ត្រពាំងថ្ម ខ្ញុំចុះទៅលេងផ្ទះបងប្អូនខ្ញុំអត់ទៅវិញៗ ពួកគ្នាខ្ញុំថាម៉េច ថាណែកុំឲ្យរត់ណា ខ្ញុំថាទេ អញមិនបានរត់ទេ ហើយមកវិញគេមកឲ្យដឹកស្រូវភ្នំស្រុក ថាឲ្យមកវិញឈប់អាត្រាក់ចាំអញនៅផ្ទះហើយណាៗ ដល់ខ្ញុំមកលេងបងប្អូនខ្ញុំ ត្រពាំងថ្មនេះ ខ្ញុំចូលទៅ គាត់មកផ្ទះគាត់ អង្គុយផ្ទះគាត់ …ខ្ញុំដើរទៅលេងផ្ទះតាៗ ទៅលេងផ្ទះតា ដល់ប្រាប់គាត់ អ៊ូ! ខ្ញុំអត់ចង់ទៅជាមួយវាទេ ជាមួយវាមិនបានឃើញមុខម៉ែទេមុខអី ហីគាត់ថាបើអ៊ែងមិនចង់ទៅ អ៊ែងទៅដេកនៅផ្ទះ

អញ ផ្ទះអញមានពីណាឡើង ហើខ្ញុំមកដេកសម្ងំនៅផ្ទះគាត់។ ដល់ពេលអាត្រាក់វាត្រឡប់មកពីដឹកស្រូវភ្នំស្រុកវិញ វាឈប់ចាំខ្ញុំមួយសន្ទុះដែរ។ ដល់វាមិនឃើញខ្ញុំទៅ វាដឹងថាខ្ញុំរត់ បើកអាត្រាក់ទៅ។

ប៊ុនថន : អាត្រាក់ទុកចោលចឹង?

ផាន : អាត្រាក់ដល់កំពង់ស្ពានហើយហ្នឹងណា ប៉ុនត្រឡប់មកដឹកស្រូវវិញ។ អាល័យធ្វើផ្លូវៗវាដាច់។ ដល់អាពេលវាដឹកក្រណាត់ អាកន្ទែងពាណិជ្ជក្នុងស្រុក អាក្រណាត់កាត់ពងពណ៌ខ្មៅៗ និយាយសម័យនោះថាពងក្រសា និយាយនៅសម័យនោះ។ អាក្រណាត់ចាប់ដែកស្រោប រាងដំទើសអីនោះណា ចាប់ដែលស្រោបដូចគឺបអីចុះហើយ ដូចថា ក្រណាត់មួយដុំអីចេះ ចាប់ដែកស្រោបត្រង់ណោះមួយៗអីចឹងទៅ។ ស្មើស្រូវមួយបាវរដ្ឋ ឲ្យតែពួកខ្ញុំលី ឲ្យតែពួកកម្មករពួកខ្ញុំ ឲ្យតែកម្មករលីសែង។ វាឈរមើល ចោះខ្ញុំគ្នាតែ៨-១០នាក់។ លីចុះពីអាត្រាក់ដាក់ក្នុងខ្ទម ប្រធានខ្ទមចម្ការគេមក ចោះរត់ទៅស្រុកគេដាក់ក្នុងខ្ទមនោះមិនអស់ វាឲ្យដាក់ដី។ ដល់ដាក់ដីរួច អស់ក្រណាត់ពីអាត្រាក់ហើយ ឲ្យស៊ីបាយៗក៏អត់មានម្ហូប បានសាច់ជ្រូកទៅពីរំចេកនេះហើយ ទៅក៏ហាន់ៗដាក់ក្នុងឆ្នាំងក៏លីងៗ ក៏នាំគ្នាស៊ីទៅ អាហូបដៃស៊ីដូចដណ្ដើមគ្នាចឹងទៅចោះមនុស្សវាច្រើន។ ស៊ីទីនោះរួច គេឲ្យមកដឹកស្រូវភ្នំស្រុកទៀត ចឹងបានថាខ្ញុំចុះនៅត្រពាំងថ្មលេងបងប្អូន។

ប៊ុនថន : ចឹងរត់ហើយ ពូអត់នៅខាងខ្មែរក្រហមទេ?

ផាន : បាទ រត់នៅខាងនោះហើយ។

ប៊ុនថន : បាទ!

ផាន : មុនដំបូងរត់ទៅនៅសំបួរ ទៅគង់ស្ពាន។

ប៊ុនថន : គង់សៀម?

ផាន : បាទ គង់សៀម។

ប៊ុនថន : គង់សៀម ហ្នឹងឃុំប្អូក៏ម៉េច?

ផាន : ទេ នៅក្នុងព្រៃណោះ ប៉ុនហៅ គង់សៀម។

ប៊ុនថន : បាទ!

ផាន : ហួសភូមិគេទៀត ហួសពង្រ ទៅដើងទៀត។

ប៊ុនថន : ចឹងនៅស្រុកភ្នំស្រុកហ្នឹងទេ?

ផាន ៖ បាទ ស្រុកភ្នំស្រុក ។ ដល់ពេលគេឲ្យមកដឹកស្រូវ អាត្រាក់៤-៥ហ្នឹងណា ។ អាមួយទៅដាច់ខ្សែពាន អាមួយធ្លាយកង់ នៅតែអាត្រាក់ពីរបី ។

ប៊ុនថន ៖ បាទ!

ផាន ៖ មានអាត្រាក់មួយមកនៅភ្នំស្រុក ប្រធាន អានោះហើយបើកមុន ។ ប្រធានគេស្ពាយការបីនមួយដើម ការបីនស្វាយបត់ ស្ពាយជិះអាត្រាក់មុន ។ ពួកអាត្រាក់ខ្ញុំនៅក្រោយតែគ្នាខ្ញុំហ្នឹង ក៏ខ្ញុំនិយាយប្រាប់ថាគ្នាខ្ញុំ ព្រោះធ្លាប់ត្រូវគ្នា ដេកក៏ចែកគ្នាដែរ ថា អ្ហ៎! អញមិននៅនេះទេ ចង់តែទៅផ្ទះ ។ ខ្ញុំប្រុងតែរត់ ពីសំបួរ ត្រពាំថ្មនេះហើយ ប៉ុនមិនហ៊ានរត់ខ្លាចវាស្ទាក់នៅខ្នងភ្នំ ស្ទាក់បានក៏ងាប់ប៉ុណ្ណឹងហើយ ។ កុំអីប្រុងរត់តែពីនេះហើយ ព្រោះខ្ញុំខ្ញុំអត់មានគំនិតចូលជាមួយវាបន្តិចទេ តាំងពីនៅជាមួយនោះ ។ បើអាខ្លះ បើអាគ្នាខ្ញុំខ្លះអាខ្លះវាថា អ្ហឺ! យើងមិនបានទៅវិញទេ ឈ្មោះ អារុង១ យើងមិនបានទៅវិញទេយ៉ាងណាឲ្យតែឃើញម៉ែបន្តិច ផ្តាំតែម៉ែយើងអត់ទៅវិញទេ ។ អានោះដែលគេបញ្ចូលធុងទៅហើយ បញ្ចូលនយោបាយគេពេញរូបអស់ហើយ ប្តេជ្ញាហើយ ។

ប៊ុនថន ៖ បាទ!

ផាន ៖ មានអីទៅក៏...ងាប់ ។ ដល់ទៅពីដងស្ទឹងទៀត យកអាត្រាក់ទៅចោលទឹកកូនខ្វែង អាហ្នឹងខ្ញុំមកវិញហើយ ប៉ុនដឹងក្រោយបានដឹង ។ យកអាត្រាក់ទៅចោលនៅកូនខ្វែង វាឲ្យពាក់កាំភ្លើង ធ្វើយោធា ។

ប៊ុនថន ៖ គេបំពាក់កាំភ្លើងឲ្យ?

ផាន ៖ អ្ហឺ! បំពាក់កាំភ្លើងឲ្យ ងាប់អស់ខ្លះឈ្មោះ អារ៉ុង ដែលខ្ញុំថាងាប់ហ្នឹង ។ អាខ្លះត្រូវមីនអាខ្លះបាញ់គ្នាក៏ងាប់ ។ កុំអីរត់ ខ្ញុំទៅក៏មានកាំភ្លើងដូចតែគ្នាហ្នឹង ។

ប៊ុនថន ៖ គង់សៀមហ្នុង ប្រធានពូដដែលពូ ប្រធានពូពីណា?

ផាន ៖ ប្រធានសុទ្ធតែពួកនិរតីហើយ ។

ប៊ុនថន ៖ ពីណាវិញពូ?

ផាន ៖ ពួកនិរតី ឈ្មោះអាអ្នកក្តាប់ខ្ញុំ លើកមុនឈ្មោះអា យ៉េន ដល់ក្រោយមកឈ្មោះអាយឿន ។ ឲ្យតែកូនក្មេង ណ៎ា! មកក្តាប់ពួកខ្ញុំ កូងក្មេងដូចថា អាយុក្មេង១ជាងខ្ញុំ ។

ប៊ុនថន ៖ បាទ!

ផាន ៖ គេអ្នកនិរតីនោះ សុទ្ធតែពួកនិរតីក្តាប់ហើយ មិនមែនពួកពាយ័ព្យទេ ។

ប៊ុនថន ៖ ចោះយាយ ចែម គាត់ទៅណា?

ផាន ៖ ទៅនោះដូចគ្នា ។

ប៊ុនថន ៖ ទៅគង់សៀមនោះដូចគ្នា?

ផាន ៖ អឺ!

ប៊ុនថន ៖ គាត់នៅណាវិញ?

ផាន ៖ ដល់អាទៅត្រង់នោះទៅ ដឹងជាទៅណាទៀត មិនដឹង បើខ្ញុំត្រឡប់មកផ្ទះ ខ្ញុំមកផ្ទះវិញ ។

ប៊ុនថន ៖ ហើពីចេញពីទៅ បានឈប់នៅផ្ទះបងប្អូនពូ?

ផាន ៖ ចេញទៅដល់ដីក រត់ទៅដល់គង់សៀមណោះ បានខ្ញុំមកដីកស្រូវបានខ្ញុំចុះនៅផ្ទះបងប្អូន ។

ប៊ុនថន ៖ នៅម្តុំណាផ្ទះគាត់?

ផាន ៖ អ្ហ៎ា!

ប៊ុនថន ៖ នៅម្តុំណាផ្ទះគាត់?

ផាន ៖ ផ្ទះបងប្អូន!

ប៊ុនថន ៖ បាទ!

ផាន ៖ ភូមិត្រពាំងថ្ម ។

ប៊ុនថន ៖ នៅត្រពាំងថ្ម?

ផាន ៖ បាទ ។

ប៊ុនថន ៖ នឹងត្រូវជាស្អីពូ?

ផាន ៖ បាទ ។

ប៊ុនថន ៖ ត្រូវជាស្អីពូ?

ផាន ៖ បងប្អូនជីដូនមួយ កូនក្មួយម៉ែខ្ញុំ គាត់បងប្អូនឆ្ងាយ រាប់អានគ្នា ។

ប៊ុនថន ៖ បាទ!

ផាន ៖ អ៊ើ! ថាបងប្អូនឆ្ងាយគ្រាន់ដែរ ប៉ុន្តែចេះតែរាប់អានគ្នា ។ មីង មានមីងបង្កើតមួយដែរ កាលហ្នឹង ប៉ុនគាត់ស្លាប់អស់ហើយ ។ ទៅក៏គាត់ នៅតែគាត់ ប្តីគាត់ស្លាប់ទៅ ក៏ឲ្យខ្ញុំទៅ ផ្ទះឈ្មោះនាយ គិនៗ គិន ងាប់ដែរសព្វថ្ងៃ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដល់ខ្ញុំទៅផ្ទះគាត់ថា នៅតែជីតា ធ្មើចម្ការឯណោះ ។ ធ្មើចម្ការ ខ្ញុំប្រាប់គាត់ថា អ្ហឺ! ខ្ញុំអត់ចង់ទៅតាមវាទេ តាមវាដឹងទៅដល់ណាទេ គាត់ថា មិនចង់ទៅតាមវា ទៅដេកផ្ទះ អញទៅមានពីឡើងឡើង អ្ហ៎ា! ផ្ទះអញ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ហើយលំទៅខ្ញុំ សម្ងំដេកផ្ទះគាត់ៗ ពេលល្ងាចចេះ កូនគាត់ឈ្មោះមី ហឿន ដែលគាត់នៅប្រជាន់នៅទួលទិលនោះ ប្រជាន់នៅវាលស្រែៗ គាត់បរទេះដឹកស្រូវទៅ ខ្ញុំជិះរទេះជាមួយបង ហឿន នោះហើយៗ ជិះពេលងងិតៗ ព្រលប់ៗ ជិះទៅជាមួយគាត់សុទ្ធតែអាគ្រាក់ អាគ្រាក់គ្នាខ្ញុំហ្នឹង ដឹកស្រូវទៅកិនត្រពាំងថ្មៗ មានដើមមិញ មានរោងម៉ាស៊ីនមួយនៅប៉ោយចារៗមានរោងម៉ាស៊ីនមួយៗ ខ្ញុំមកទៅគេ ទៅដឹកស្រូវនៅភ្នំស្រុកហ្នឹងឯង យកមកកិនអង្ករនេះៗ ទៅក៏ ខ្ញុំថាបង ហឿន បរទេះឲ្យលឿនទៅ ថាឲ្យគាត់បរទេះឲ្យលឿន ខ្លាចអាគ្រាក់ ខ្លាចគ្នាឯងផាកឃើញៗ

ប៊ុនថន ៖ បាទ!

ផាន ៖ ប៉ុនវារៀងងងិតគ្រាន់ហើយ ខ្ញុំមកដេកនៅជាមួយអ្នកបញ្ជាន់អ្នកប្រូតនោះ ទួលទិលនោះៗ មកដល់កុហក់ប្រធាននោះទៀតៗ

ប៊ុនថន ៖ ទួលពិល?

ផាន ៖ ទិលៗ

ប៊ុនថន ៖ ទួលទិល?

ផាន ៖ បាទៗ

ប៊ុនថន ៖ នៅភូមិណាវិញពូ?

ផាន ៖ អត់មានភូមិទេៗ

ប៊ុនថន ៖ ប៉ុនឃុំណាមើលទៅ?

ផាន ៖ នៅឃុំប៉ោយចារ ទួលពិលនោះវាលស្រែៗ វាលស្រែមានដើមពោធិមួយដើម គេហៅថាទួលទិលៗ ប្រជាជនមកដេកបញ្ជាន់ ដេកប្រូតៗ ដល់ខ្ញុំដេកជាមួយគេនោះហើយ មកដល់ខ្ញុំកុហក់ប្រធានៗ

ប៊ុនថន ៖ ប្រធាន?

ផាន ៖ ប្រធានក្តាប់រួមគេ ប្រូតបញ្ជាន់កន្លែងនោះ កុហក់គេថា គេសួរថា ប្អូនឯងមកពីណា ខ្ញុំថានៅចល័តភ្នំលាបវែថ្ម ដល់ពេលវៀតណាមចូលមក គេរត់អស់ទៅហើយក៏ខ្ញុំដឹងមកណាក៏ខ្ញុំមកផ្ទះៗ ហើគាត់ថា មានប្អូនឯង បើខ្ញុំថា កាលពីមិនទាន់វៀតណាមចូលគេអត់ឲ្យខ្ញុំកាន់កាំភ្លើងទេ អាប្រធាននោះ ណ៎! ដល់ពេលវៀតណាម ដល់ពេលដ្អើលឲ្យខ្ញុំកាន់កាំភ្លើង ឯងមិនកាន់ថា ឯងខ្លាំងៗ អាពួកគាត់អ្នកក្តាប់នោះ គាត់មកពីនិរតីដូចគ្នា បើមិន

និរតីទេ ពួកកំពង់ឆ្នាំង អត់មានអ្នកពាយ័ព្យយើងទេណាក្តាប់ៗ ប៉ុនគាត់អត់ចូលខាងវា នោះទេ អត់ទៅចូលទេៗ

ប៊ុនថន : ឈ្មោះអីវិញ?

ផាន : អត់ស្គាល់ឈ្មោះគាត់ទេខ្ញុំៗ គាត់ទៅសួរគាត់ ដេកជាមួយគាត់ម៉ាល្ងាចនោះឯងៗ ហីគាត់ថា បើឯងមិនទៅជាមួយវា ថាឯងខ្មាំង ហើយគាត់ថា ខ្ញុំអត់ចង់ទៅជាមួយវាទេ ខ្ញុំអត់ចង់កាន់កាំភ្លើងទេៗ ថាឯងមិនទៅថាឯងខ្មាំង និយាយប្រាប់ខ្ញុំកុហក់ ព្រោះខ្ញុំកុហក់គាត់ថានៅវាយថ្ម គេរត់អស់ហើយ មិនដឹងទៅណាក៏ខ្ញុំមកផ្ទះៗ យប់ឡើង ខ្ញុំដើរមកផ្ទះគាត់វាល គាត់វាលត្រពាំងថ្មនោះឯងៗ

ប៊ុនថន : មកជួបឪពុកម្តាយទេពូ?

ផាន : ឪពុកម្តាយនៅផ្ទះនេះៗ មកខ្ញុំមកនៅ គេហៅ សង្កែដោចៗ អ្នកភូមិខ្ញុំទៅនៅដេកប្រូត ដេកបញ្ជាន់នោះហើយៗ មកក៏នៅស៊ីបាយស៊ីហ្នឹងគេហើយ បានខ្ញុំដើរមកផ្ទះៗ មកផ្ទះក៏មិនបាននៅយូរៗ

ប៊ុនថន : ម៉េចចឹង?

ផាន : ដេកផ្ទះមួយយប់ទៅ ខ្លាចគេទៀតខ្លាចៗ នៅសម្ងំនោះ យកឯងវាយចោលទៀតៗ ដេកផ្ទះមួយយប់ ព្រឹកឡើងខ្ញុំទៅនៅនោះហើយ ដេកប្រូតហ្នឹងគេៗ

ប៊ុនថន : ដេកប្រូតនៅណា?

ផាន : ដេកប្រូតនៅសង្កែដោចៗ

ប៊ុនថន : សង្កែដោច?

ផាន : បាទ ជាមួយប្រជាជន ដេកបញ្ជាន់នៅនោះហើយៗ ខ្ញុំដេកផ្ទះខ្លាចគេតាមដានយើងយកឯងទៅវាយចោលទៀត ថាឯងសម្ងំសុខអីទៀត ដែលបាននៅអាសម័យនោះៗ

ប៊ុនថន : បានជួបឪពុកម្តាយនៅផ្ទះ?

ផាន : ជួប ឪពុកម្តាយខ្ញុំនៅផ្ទះៗ ដល់អាទៅនៅដេកជាមួយគេឯង ប៉ុនខ្ញុំមកពីនោះគេមិនឲ្យខ្ញុំរត់ផង ខ្ញុំភ័យដែរនោះ ខ្លាចអានោះឲ្យដំណឹងម៉េចៗទៅ តាមឯងវាយចោលទៀតៗ

ប៊ុនថន : បាទ!

ផាន : ចោះតែខ្លាចខ្លួនអញ្ចោះៗ

ប៊ុនថន : ចឹងកាលហ្នឹងនៅខាងខ្មែរក្រហមទេ?

ផាន : ខាងខ្មែរក្រហមៗ

ប៊ុនថន ៖ វៀតណាមអត់ទាន់ចូលមកទេ?

ផាន ៖ វៀតណាមចូលហើយ ប៉ុនវៀតណាមដើរតែតាមថ្នល់ជាតិ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ដល់តែចុះមកនេះនៅតែខ្មែរក្រហមក្តាប់ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ទាល់យូរទៅវៀតណាមចុះមកតាមភូមិនេះ បានហ៊ានរត់ ។

ប៊ុនថន ៖ រហូតដល់ឆ្នាំប៉ុន្មានពូ?

ផាន ៖ ប៉ុន្មានទេ ដែលវៀតណាមចូល៧៩ ។

ប៊ុនថន ៖ បាទ ៧៩ ដែរ?

ផាន ៖ ហ្នឹងហើយ ឆ្នាំ៧៩ ។ ៧៩ ដូចថាវាមិនហ៊ាននៅរាប់ឆ្នាំទេ វាចូលបានមកដូចថានៅត្រឹមកន្លះខែ ឬមួយខែអីវៀតណាមរំដោះពេលនោះ ណា៎! មិនបាននៅយូរ ។

ប៊ុនថន ៖ សន្តែដោចនៅបានរយៈពេលប៉ុន្មានបានវៀតណាមចូលមក?

ផាន ៖ ខ្ញុំនៅបាន បានរយៈប្រហែលកន្លះខែដីង ប៉ុណ្ណោះដែលរត់មក ។

ប៊ុនថន ៖ កន្លះខែពូ?

ផាន ៖ វាផ្អើល១ ភូមិនេះដែល១ខ្លាចពួកអាអ្នកក្តាប់១ហ្នឹងណា ដែលខ្លាចពួកអាអ្នកក្តាប់ ដែលវាទៅយកកាំភ្លើងពីភ្នំស្រុកមក ដល់វាយកមកកាន់តែគ្នាវា ណា៎! អ្នកខ្លាចវាចាប់វាយចោល ភូមិនេះរត់ទៅស្វាយ ។

ប៊ុនថន ៖ រត់ទៅស្វាយ?

ផាន ៖ ដល់រត់ទៅស្វាយ អីណោះ ដូចថា អន្តអីណោះគេឲ្យកាំភ្លើងកាន់ ឲ្យកាំភ្លើងកាន់មក ពួកខ្ញុំស្ទាក់បាញ់វានៅនេះហើយ ហើយបានផ្អើលរត់បណ្តោយ ។ ហីក៏រត់ថ្ងៃនេះហើយ ខ្ញុំក៏រត់មកសន្តែដោចចូលទៅ ហីក៏រត់ពីណោះ ទៅជប់ ទៅអីណោះទៅរកថ្នល់ជាតិទាំងអស់គ្នា បរទេះរត់ទៅភូមិ ។

ប៊ុនថន ៖ បាញ់ខ្មែរក្រហមវិញ?

ផាន ៖ អ្ហើ! បាញ់អាពួកអ្នកក្តាប់ អ្នកដឹក ណែវាមកចាប់តា ចាប់អីទៅ ។ ដល់វាខ្លាចខ្លួនវា វាឈប់ហ៊ាននៅនេះ ស្អីវាទៅណា ទៅដើងអីណោះ ។ ដល់មួយថ្ងៃពីថ្ងៃ វាមកដឹកជ្រូកដឹកតា ដល់ពេលនោះ យើងដែលរត់ទៅណោះបានកាំភ្លើង មកស្ទាក់បាញ់វាក៏រត់ ។ ដេញឡើងប៉ុន្តែដេញវាមិនទាន់ ។

ប៊ុនថន : ចឹងពូចូល តាំងពីហ្នឹងមកពូចូលភូមិ មកនៅភូមិរហូត?

ផាន : អ្ហ៎! រត់នៅយូរណា រត់ទៅថ្នល់ណា ខ្ញុំថារាប់ខែដឹងរត់ មួយប្រាំង។ ទៅរួច មិនដែលបានមកផ្ទះវិញ។

ប៊ុនថន : បាទ!

ផាន : ហើយវៀតណាមមិនទាន់មកឯណា មិនទាន់មកនៅដល់ភូមិនេះ។ ចេះតែខ្លាចពួកខ្មែរក្រហមរត់ទៅឆ្ងាយ មិនហ៊ានមកដល់ភូមិនេះ បានប្រជាជនហ៊ានមកនៅភូមិនេះ។

ប៊ុនថន : ចឹងវៀតណាមចូលមកឆ្នាំប៉ុន្មាន?

ផាន : ទេ ប៉ុន្មាន មិន៧៩ទេ។

ប៊ុនថន : បាទ ៧៩!

ផាន : ៧៩ ។

ប៊ុនថន : ហើពូនៅភូមិនេះរហូតពូចាប់ពីហ្នឹងមក?

ផាន : នៅរហូត។

ប៊ុនថន : ពូការឆ្នាំណា?

ផាន : អ្ហ៎!

ប៊ុនថន : ពូរៀបការឆ្នាំប៉ុន្មានពូ?

ផាន : ដឹងឆ្នាំប៉ុន្មាន ភ្លេចហើយ អាឆ្នាំដែលខ្មែរគេ។

ប៊ុនថន : ក្រោយហើយ ក្រោយ៧៩ហើយ?

ផាន : បាទ ក្រោយបន្តិច ឆ្នាំ៧៩ហ្នឹងឯង។ អាសម័យដែលវៀតណាមចូលនោះហើយ សម័យទៅដឹកអង្ករ សម័យនោះឯង។

ប៊ុនថន : សព្វថ្ងៃកូនអីប៉ុន្មាននាក់?

ផាន : កូនប្រាំនាក់។

ប៊ុនថន : ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ផាន : ស្រីទាំងអស់។

ប៊ុនថន : តែនៅរៀននៅអីទេ?

ផាន : នៅរៀនមួយនៅស្វាយ ប៉ុន្តែចេញឆ្នាំនេះឯង ធ្វើគ្រូ។

ប៊ុនថន : ហើយក្រៅពីហ្នឹង?

ផាន : ក្រៅពីហ្នុងធ្វើស្រែ។

ប៊ុនថន ៖	មានគ្រួសារប៉ុន្មានហើយ?

ផាន ៖	នៅមីក្រោយមួយទៀត នៅរៀនថ្នាក់ទី៦ ។ គ្រួសារស្លាប់អស់ទៅហើយ នៅខ្លួនឯង ។

ប៊ុនថន ៖	អូ៎! គ្រួសារស្លាប់ហើយ?

ផាន ៖	បាទ គាត់ស្លាប់ខ្ញុំបានពីរនាក់ហ្នឹង ស្លាប់អស់ទាំងពីរនាក់ ។ កាលលើកមុនវាឆ្លងទន្លេទៅយើងមិនទាន់មានពេទ្យឆ្មប ដល់គ្នាអត់រួចក៏ស្លាប់ ។

ប៊ុនថន ៖	បាទ!

ផាន ៖	ក្រោយមកកើតអាជំងឺបៀមហារីកដោះ អត់មើលជា គិតថាយើងមិនបាន ដល់ថាអាពកតូចៗ យើងមិនបានទៅពិនិត្យពេទ្យ ។ មិនសូវដឹងផងសម័យកាលណោះ ដូចសព្វថ្ងៃមានហើយ ។

ប៊ុនថន ៖	ចោះផ្ទះពូនៅណាវិញ?

ផាន ៖	នៅត្រង់នោះ អាផ្លូវនេះទៅត្បូង ។

ប៊ុនថន ៖	ចឹងនៅ ហីកូនមានគ្រួសារខ្លះនៅពូ?

ផាន ៖	មានបីនាក់ហើយ នៅពីរនាក់ ។

ប៊ុនថន ៖	ចោះពូមានអីចង់បន្ថែមទៀតទេពូ?

ផាន ៖	មានអីទេ ។

ប៊ុនថន ៖	ចឹងខ្ញុំអរគុណពូច្រើនហើយ អស់អីសួរពូ ។

«ចប់»